N: 20

31-5-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ២០ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៧

OFFICIAL JOURNAL

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LM

មាតិកា

I-រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៨-៥-១៩៩៧ –អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១១៤២

២៨-៥-១៩៩៧ –អនុក្រឹត្យលេខ ២០ អនក្រ.បក ស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ១១៥៣

II-ការងារបណ្តាក្រសួង

១-និស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

៣០-៥-១៩៩៧ –ប្រកាសលេខ ៣៤១ ប្រកសហវ.ពជ ស្តីពីអាករពិសេសលើទំនិញ ១១៥៧

៣០-៥-១៩៩៧ –ប្រកាសលេខ ៣៤២ ប្រកសហវ.ពជ ស្តីពីអាករលើផលរបរ ១១៨២

២-និស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

២៧-៥-១៩៩៧ –ប្រកាសលេខ ១៥០ ពណ.ពកបប្រក បំពេញបន្ថែមក្នុងប្រកាសលេខ ៣៥០ ពណ.ពកប ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ១៩៩៦ ១១៩៨

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៧-៥-១៩៩៧	-ប្រកាសលេខ ៤៧៧ ស្តនផក.ប្រក អនុញ្ញាតអោយ លោក គៀង អៀងគារ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការសិប្បកម្មផលិតកាហ្វេ និង តែ	១២០៤
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៧៨ ស្តនផក.ប្រក អនុញ្ញាតអោយ លោក ស្រេង អៀង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការសិប្បកម្មផលិតតែកញ្ចប់	១២០៥
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៧៩ ស្តនផក.ប្រក អនុញ្ញាតអោយ លោក ស្រេង វី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការសិប្បកម្មផលិតតែកញ្ចប់	១២០៦
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨០ ស្តនផក.ប្រក អនុញ្ញាតអោយ អ្នកស្រី ទៅ ចាន់ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ	១២០៧
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨១ ស្តនផក.ប្រក អនុញ្ញាតអោយ លោក យុត ជៀង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥០ សេះ	១២០៨
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨២ ស្តនផក.ប្រក អនុញ្ញាតអោយ លោក តាំង ហួត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥៧ សេះ	១២០៨
៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឌុច គីមលឿន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១០៩ សេះ	១២០៩

២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៤ ផក.ប្រក អនុញ្ញាតអោយលោក គីម យ៉ិន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងជាងផ្សារដែក	១២១០
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៥ ផក.ប្រក អនុញ្ញាតអោយលោក លៀង គុង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងជាងក្រឡឹង និងផ្សារដែក	១២១០
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៦ ផក.ប្រក អនុញ្ញាតអោយលោក ឡុយ និច ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ	១២១១
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៧ ផក.ប្រក អនុញ្ញាតអោយលោក ជី គុងងួន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ	១២១១
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៨ ផក.ប្រក អនុញ្ញាតអោយលោក លៀង ឈាង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៩០ សេះ	១២១២
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៨៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អ៊ុក ស ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ	១២១៣
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៩០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី នួន ប៊ិច ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ	១២១៣
២៧-៥-១៩៩៧	-ប្រកាសលេខ ៤៩១ ផក.ប្រក អនុញ្ញាតអោយលោក ម៉ឺង ឈៀង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ	១២១៤

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩២ ផក.ប្រក អនុញ្ញាតអោយលោក
ម៉ក់ សុផាត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ១២១៥

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី
ណារ៉ៈ ហ៊ិញ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ ១២១៥

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៤ ផក.ប្រក អនុញ្ញាតអោយលោក
ម្សេង ឆេង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ៩០ សេះ ១២១៦

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៥ ផក.ប្រក អនុញ្ញាតអោយលោក
អេង កុយ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ ១២១៧

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៦ ផក.ប្រក អនុញ្ញាតអោយលោក
សុខ អ៊ិន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២ សេះ ១២១៧

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៧ ផក.ប្រក អនុញ្ញាតអោយលោក
ហែម កៃ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្តដំណើរ
ការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥៥ សេះ ១២១៨

២៧-៥-១៩៩៧ –ប្រកាសលេខ ៤៩៨ ផក.ប្រក អនុញ្ញាតអោយលោក
កែង សុផាន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា បន្ត
ដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៥៥ សេះ ១២១៩

២៨-៥-១៩៩៧ –ប្រកាសលេខ ៥០០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី
លឹម ហុង ជាម្ចាស់មូលដ្ឋានផលិតទឹកកកដើម ប្តូរទី
តាំងផលិតកម្មទៅកាន់ទីតាំងថ្មី ១២១៩

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

៣០-៥-១៩៩៧	-ប្រកាសលេខ ៤១២ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា «ភូមិថ្មី» ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា «ធ្លាត់»	១២២១
៣០-៥-១៩៩៧	-ប្រកាសលេខ ៤១៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា«ត» មកជាសាលាបឋមសិក្សា«ប៊ុនរ៉ាតី ហ៊ុនសែន ឃុំតរ» វិញ	១២២៣

៥-ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

២៩-៥-១៩៩៧	-សេចក្តីសំរេចលេខ ១១០/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមជំនុំបេសកកម្ម សេចក្តីមេត្តាករុណា ឈ្មោះក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រិស្ត ភូមិ ស្វាយតាយាន	១២២៤
២៩-៥-១៩៩៧	-សេចក្តីសំរេចលេខ ១១១/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមប្រិយសម្ព័ន្ធបរិស័ទកម្ពុជាឈ្មោះ «ក្រុមជំនុំជីវិតថ្មី»	១២២៦
២៩-៥-១៩៩៧	-សេចក្តីសំរេចលេខ ១១២/៩៧ កធស អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយប្រូតេស្តង់ ក្រុមសម្ព័ន្ធគ្រិស្តានដំណឹងល្អខ្មែរឈ្មោះ«ពន្លកថ្មី-ព្រែកថ្មី»	១២២៨

* * * * *

I- រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧

អនុក្រឹត្យលេខ ១៩ អនក្រ.បក

ស្តីពី

ការរៀបចំ និង ការប្រព្រឹត្តិទៅ

របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០.៩៤/៨៣/ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០.៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង.និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី ។

សម្រេច

ជំពូក ១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះ រៀបចំបណ្តាអង្គភាពនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង កំណត់បេសកកម្មរបស់រដ្ឋលេខាធិការដ្ឋាន និងអង្គភាព[illegible]ន ។

ជំពូក២

បេសកកម្ម និងរចនាសម្ព័ន្ធ

មាត្រា ២ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវបានគណៈរដ្ឋមន្ត្រី ប្រគល់អោយទទួលបន្ទុកបេសកកម្មដឹកនាំ និង គ្រប់គ្រងមន្ត្រីរាជការស៊ីវិលលើវិស័យមុខងារសាធារណៈ ។

មាត្រា ៣ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមានមុខងារ និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ រៀបចំតាក់តែង និង តាមដានការអនុវត្តលិខិតបទដ្ឋានច្បាប់ និង បទបញ្ជានានា ដែលមានចែងក្នុងច្បាប់ សហលក្ខន្តិកៈ ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។
- ផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រីលើគ្រប់សេចក្តីព្រាងលិខិតបទដ្ឋានស្តីពីការបង្កើត និងការកែសំរួលនូវការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងស្ថាប័ននានា ។
- គ្រប់គ្រងក្របខ័ណ្ឌ និងគ្រប់គ្រងផែនការក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ។

- លើកសំណើ និងតាមដានការអនុវត្តន៍នូវគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សរបស់រដ្ឋ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីរាជការស៊ីវិល ។
- លើកសំណើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីចំនួនក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ ក្រោយពីបានពិនិត្យពិភាក្សា បូកសរុបដោយផ្អែកលើសំណើរបស់ក្រសួងនានា និង តាមដានការអនុវត្តន៍លើបញ្ហានេះ ។
- ត្រួតពិនិត្យនិយតភាពនៃការរៀបចំ និងកិច្ចដំណើរការនៃការប្រឡងជ្រើសរើសចូលក្នុងក្របខ័ណ្ឌរដ្ឋរបស់ក្រសួងស្ថាប័ននានាស្របតាមមាត្រា១៥នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។
- ផ្ទៀងផ្ទាត់លើសេចក្តីព្រាងលិខិតបទដ្ឋានឯកត្តជនក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលស្នើឡើង ដោយក្រសួងស្ថាប័ននានា ពោលគឺព្រះរាជក្រឹត្យ និង អនុក្រឹត្យ ។ ចំពោះប្រកាសរបស់ក្រសួង ស្ថាប័ននានា ត្រូវតែមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈថែមទៀត ។
- រៀបចំបង្កើតនូវតារាងពត៌មានលើការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋ ។
- ពិនិត្យរាល់ពាក្យបណ្តឹងតវ៉ារបស់មន្ត្រីរាជការស៊ីវិលទូទៅ ដែលមានវិវាទពាក់ព័ន្ធទៅនឹងកិច្ចការមុខងារសាធារណៈ ដើម្បីដាក់ជូនគណៈកម្មការសំរុះសំរួលវិវាទពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ។
- សិក្សាស្រាវជ្រាវ រៀបចំសេចក្តីព្រាង និងលើកសំណើ ស្តីពីគោលនយោបាយលាភការផ្សេងៗ របស់មន្ត្រីរាជការស៊ីវិល ។
- រក្សាទុកឯកសាររដ្ឋបាលក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។

មាត្រា ៤ : រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈមានរចនាសម្ព័ន្ធ ដូចតទៅ :

- ខុទ្ទកាល័យ
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានមុខងារសាធារណៈមាននាយកដ្ឋានចំណុះចំនួន៣ និង ការិយាល័យចំនួន២ ។

អង្គភាពលេខារបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

ជំពូក ៣

ខុទ្ទកាល័យរដ្ឋលេខាធិការ

មាត្រា ៥ : ខុទ្ទកាល័យរដ្ឋលេខាធិការទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ជំពូក ៤

អគ្គាធិការដ្ឋាន

មាត្រា ៦ : អគ្គាធិការដ្ឋានរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ទទួលបន្ទុក :

- ត្រួតពិនិត្យរដ្ឋបាល ស្តីពីការគ្រប់គ្រងមន្ត្រីរាជការ លើការគោរពនូវរាល់នីតិវិធីការអនុវត្តន៍ច្បាប់ និងបទបញ្ញា
- ផ្តល់យោបល់ដល់ប្រធានអង្គភាពរដ្ឋបាលនៃស្ថាប័ននានា លើបញ្ហាគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋក្នុងករណីដែលមានការខ្វះខាតក្នុងការអនុវត្តន៍គោលការណ៍
- រាយការណ៍ជូនរដ្ឋលេខាធិការ ពីការអនុវត្តន៍លិខិតបទដ្ឋាន និងវិធានគ្រប់គ្រងនានាក្នុងគោលដៅកែលំអទស្សនៈនយោបាយ និង ភារកិច្ចត្រួតពិនិត្យដែលរដ្ឋលេខាធិការប្រគល់អោយ អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូបអមដោយអគ្គាធិការរង និងអធិការជាជំនួយការ ។

ជំពូក ៥

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៧ : នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុទទួលបន្ទុក :

ក–ក្នុងវិស័យរដ្ឋបាល :

– សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់រដ្ឋលេខាធិការដ្ឋាន

– គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន

– ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់រដ្ឋលេខាធិការដ្ឋាន

– សរុបនិងធ្វើរបាយការណ៍ការងារ និង សកម្មភាពផ្សេងៗរបស់រដ្ឋលេខាធិការដ្ឋាន។

ខ–ក្នុងវិស័យគ្រប់គ្រងបុគ្គលិក :

– គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់រដ្ឋលេខាធិការដ្ឋាន

– រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងក្របខ័ណ្ឌ

– រៀបចំផែនការក្របខ័ណ្ឌ និងធនធានមនុស្សរបស់រដ្ឋលេខាធិការដ្ឋាន

– រៀបចំនយោបាយបណ្តុះបណ្តាល តាមដានការអនុវត្តន៍និងវាយតំលៃតំរូវការបណ្តុះបណ្តាលបុគ្គលិក

– រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មាន ។

គ–ក្នុងវិស័យគ្រប់គ្រងសំភារៈ និងបរិក្ខារ :

– ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និង បរិក្ខាររបស់រដ្ឋលេខាធិការដ្ឋាន

– គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

– គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនរដ្ឋលេខាធិការដ្ឋាន ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់

- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្ដាអង្គភាពក្រោមឱវាទ
- កាន់បញ្ជីជាប្រចាំនូវសំណាកបប័ត្រ និងគណនេយ្យរូបធាតុ
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

ឃ-ក្នុងវិស័យគ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ :

- លើកគំរោងថវិការបស់រដ្ឋលេខាធិការដ្ឋាន និងតាមដានវិលើកពីការប្រតិបត្តិ
- ប្រមូលផ្ដុំ និងសំរបសំរួលជំពូកថវិកា
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្ដុំ និងសំរបសំរួលរាល់ចំណាយរបស់រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

ជំពូក ៦

អគ្គនាយកដ្ឋានមុខងារសាធារណៈ

មាត្រា ៨ : អគ្គនាយកដ្ឋានមុខងារសាធារណៈទទួលបន្ទុក សម្របសម្រួលសកម្មភាពក្នុងដំណើរការរបស់នាយកដ្ឋានក្រោមឱវាទនានា ។

អគ្គនាយកដ្ឋានមុខងារសាធារណៈរួមមាន ÷

- នាយកដ្ឋាននីតិកម្ម និង វិវាទមុខងារសាធារណៈ
- នាយកដ្ឋានក្របខ័ណ្ឌសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល
- នាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល និងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ការិយាល័យឯកសារ
- ការិយាល័យពត៌មានវិទ្យា អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូបអមដោយអគ្គនាយករងជាជំនួយការ ។

មាត្រា ៩ : នាយកដ្ឋាននីតិកម្ម និង វិវាទមុខងារសាធារណៈទទួលបន្ទុក ÷

- សម្របសម្រួលត្រួតពិនិត្យលើការរៀបរៀង និងតាមដានការរៀបរៀងលិខិតបទដ្ឋាននៃនីតិវិធី គ្រប់គ្រងមន្ត្រីរាជការស៊ីវិលរបស់បណ្ដាក្រសួងស្ថាប័ន

- សិក្សាស្រាវជ្រាវរៀបចំតាក់តែងលើកសំណើ សំដៅពង្រឹង កែសម្រួលលិខិតបទដ្ឋាននៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ធ្វើការត្រួតពិនិត្យ និងធ្វើសុពលភាពលើសំណើរបស់បណ្ដាក្រសួង ស្ដីពីលក្ខន្តិកៈដោយឡែក
- ផ្ដល់យោបល់ជូនគណៈរដ្ឋមន្ត្រី លើគ្រប់សេចក្ដីព្រាងលិខិតបទដ្ឋាន ស្ដីពីការបង្កើត និងការកែសម្រួលនូវការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រសួងស្ថាប័ន
- សិក្សាស្រាវជ្រាវ លើកសំណើស្ដីពីគោលនយោបាយលាភការផ្សេងៗរបស់មន្ត្រីរាជការស៊ីវិល
- រៀបចំសារណាសំរាប់ការពារនៅក្នុងការជំនុំជំរះគាត់ក្ដីក្នុងករណីវិវាទមុខងារសាធារណៈ ។

មាត្រា១០: នាយកដ្ឋានក្របខ័ណ្ឌ សិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាលទទួលបន្ទុក :

- គ្រប់គ្រងនូវតារាងព្យាករណ៍ចំនួនតំណែង ចំនួនក្របខ័ណ្ឌ និងកំណត់ចំនួនទៅតាមស្ថានភាពភូមិសាស្ត្រ ព្រមទាំងធ្វើការតាមដានការវិវត្តន៍រយៈពេលខ្លី មធ្យម និងរយៈពេលវែង ដោយផ្អែកទៅលើការគ្រប់គ្រងចំនួនតំណែង ចំនួនក្របខ័ណ្ឌ និង កំណត់ចំនួនទាំងនេះទៅតាមស្ថានភាពភូមិសាស្ត្ររបស់ក្រសួងស្ថាប័ន ។ តារាងនេះត្រូវបាន រៀបចំឡើងដោយផ្អែកទៅតាមគោលនយោបាយរួម និង ទិសដៅដែលកំណត់សំរាប់មុខងារសាធារណៈ ។
- លើកសំណើឡើងវិញ អំពីក្របខ័ណ្ឌទៅតាមការវិវត្តន៍ដែលបានគ្រោងទុកស្ដីពីតំណែងការងារ ។
- លើកទិសដៅ និង ដាក់អោយអនុវត្តនូវផែនការស្ដីពីការបណ្ដុះបណ្ដាលមន្ត្រីរាជការស៊ីវិលក្នុងវិស័យគ្រប់គ្រងក្របខ័ណ្ឌដោយបំពេញមុខងារដូចខាងក្រោម:
    * សម្របសម្រួល និងសហការជាមួយស្ថាប័នពាក់ព័ន្ធ អំពីការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ ការងារវិក្រឹតការ សុក្រឹតការ និងការបណ្ដុះបណ្ដាលអចិន្ត្រៃយ៍នៃមន្ត្រីរាជការស៊ីវិល
    * ផ្ដល់យោបល់លើសំណើកែតម្រូវគោលនយោបាយអប់រំរយៈពេលមធ្យម ឬ រយៈពេលវែង

* សហការជាមួយសាលាភូមិន្ទរដ្ឋបាលលើកម្មវិធី និង ផែនការបណ្តុះបណ្តាល។

– ត្រួតពិនិត្យនិយតភាពនៃការរៀបចំ និងកិច្ចដំណើរការនៃការប្រឡងជ្រើសរើសចូលក្នុងក្របខ័ណ្ឌរដ្ឋរបស់ក្រសួងស្ថាប័ន។

– បង្កើតតារាងពត៌មានស្តីពីការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋ និងលើកសំណើស្តីពីសកម្មភាព។

មាត្រា១១: នាយកដ្ឋានត្រួតពិនិត្យរដ្ឋបាល និងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលទទួលបន្ទុក ៖

– ផ្ទៀងផ្ទាត់សុពលភាពរដ្ឋបាលសេចក្តីព្រាងលិខិតបទដ្ឋានឯកត្តជនក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលជាអនុក្រឹត្យ និងព្រះរាជក្រឹត្យទៅនឹងច្បាប់សហលក្ខន្តិកៈ លក្ខន្តិកៈដោយឡែក និង លិខិតបទដ្ឋានផ្សេងៗ ហើយដាក់ជូនប្រធានស្ថាប័នមុខងារសាធារណៈចុះទិដ្ឋាការលើសេចក្តីព្រាងទាំងនោះមុននឹងជូនទៅនាយករដ្ឋមន្ត្រី ។

– ត្រួតពិនិត្យសុពលភាពរដ្ឋបាលលើលិខិតឯកត្តជនក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលជាប្រកាសរបស់ក្រសួង ស្ថាប័ននានា ដោយដាក់ជូនប្រធានស្ថាប័នមុខងារសាធារណៈ ចុះទិដ្ឋាការលើប្រកាសនោះ ។

– ទទួលខុសត្រូវលើសលាកបត្ររបស់មន្ត្រីរាជការស៊ីវិល ដែលបានប្រមូលផ្តុំនៅរដ្ឋលេខាធិការដ្ឋាន ។

– បូកសរុបការប្រែប្រួលស្ថានភាពមន្ត្រីរាជការស៊ីវិល និងស្ថានភាពគ្រួសារ ។

មាត្រា១២: ការិយាល័យឯកសារមានភារកិច្ចរក្សាទុកឯកសាររដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល ។ សំណុំលិខិតនីមួយៗ អាចបង្កបង្កើតឡើងតាមផ្លូវច្បាប់ នូវប្រវត្តិអាជីពរបស់មន្ត្រីរាជការម្នាក់ៗ ហើយត្រូវមានគ្រប់លិខិតស្នាម គ្រប់គ្រងដែលពាក់ព័ន្ធដល់មន្ត្រីរាជការនោះមួយច្បាប់ៗ ជាផ្លូវការទាំងអស់។

មាត្រា១៣: ការិយាល័យពត៌មានវិទ្យា មានភារកិច្ច ÷

- គ្រប់គ្រងលើធនធានពត៌មានវិទ្យានៃរដ្ឋលេខាធិការដ្ឋាន ស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ធានាឆ្លងឆ្លើយផ្នែកពត៌មានវិទ្យាទៅគ្រប់ក្រសួង ស្ថាប័នស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ធានាការថែទាំជាប្រចាំលើប្រព័ន្ធកម្មវិធីនិងសំភារៈពត៌មានវិទ្យាដែលប្រើប្រាស់លើការងារគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។

ជំពូក ៧
អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា១៤: អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

ជំពូក ៨
អវសានប្បញ្ញត្តិ

មាត្រា១៥: ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា១៦: បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៧: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ

ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

សូមបង្គំទូលថ្វាយនិងជំរាបជូន:

-សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

-សម្តេចនាយករដ្ឋមន្ត្រីទី២

រដ្ឋលេខាធិការ

នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រាក់ សុខ

* * * * *

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ : ១៩ អនក្រ.បក

ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧

អង្គការលេខ

នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ



រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៧

អនុក្រឹត្យ លេខ២០ អនក្រ.បក

ស្តីពី

គោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ
- តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី។

សម្រេច

ជំពូក ១

នីតិវិធីនៃការគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញវត្ថុរបស់មន្ត្រីរាជការស៊ីវិល

មាត្រា ១ : សេចក្ដីព្រាងលិខិតបទដ្ឋានឯកត្តជនក្នុងការគ្រប់គ្រងរដ្ឋបាលមន្ត្រីរាជការស៊ីវិល ពោលគឺព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ត្រូវធ្វើឡើងនៅរដ្ឋបាលកណ្ដាល តាមរយៈអង្គភាពទទួលបន្ទុកបុគ្គលិក នៅលើឯកសារពត៌មានវិទ្យាគំរូ និងត្រូវបញ្ជាក់អត្តលេខរបស់មន្ត្រីរាជការទាំងនោះ ។ ចាប់ពីពេលដែលដាក់អោយដំណើរការ នូវប្រព័ន្ធគ្រប់គ្រងតាមពត៌មានវិទ្យាតទៅ លិខិតបទដ្ឋានឯកត្តជនដែលបោះពុម្ពតាមស្តង់ស៊ីលឬសរសេរដោយដៃត្រូវចាត់ទុកជាទុព្វលភាព ។

មាត្រា ២ : លិខិតបទដ្ឋានឯកត្តជនខាងលើនេះ ត្រូវផ្ទៀងផ្ទាត់លើសុពលភាព ផ្នែករដ្ឋបាល ដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង លើផ្នែកថវិកាដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលត្រូវចុះទិដ្ឋាការរៀងៗខ្លួនលើលិខិតបទដ្ឋានឯកត្តជនទាំងនោះ ។ ការចុះទិដ្ឋាការ លើសេចក្ដីព្រាងអនុក្រឹត្យ និង ព្រះរាជក្រឹត្យ ត្រូវចុះទៅក្នុងមូលបទ ។ ចំពោះប្រកាស ទិដ្ឋាការរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចុះនៅផ្នែកខាងឆ្វេងនៃហត្ថលេខារបស់ប្រធានស្ថាប័នសាមី ។

មាត្រា ៣ : ប្រាក់បៀវត្ស និង ប្រាក់បំណាច់ផ្សេងៗ ដែលត្រូវបើកអោយមន្ត្រីរាជការស៊ីវិល ត្រូវទូទាត់និងបើក ដោយគណនេយ្យករនៃរតនាគារ ដោយពុំបាច់មានអាណាប័ណ្ណជាមុនឡើយ ។ ការទូទាត់ត្រូវធ្វើឡើង ដោយម៉ាស៊ីនកុំព្យូទ័រនៅថ្នាក់កណ្ដាល ដែលទ្រទ្រង់ប្រព័ន្ធគ្រប់គ្រងក្រោមការត្រួតពិនិត្យរបស់រតនាគារ ដែល

អនុវត្តក្នុងឋានៈជាគណនេយ្យករសាធារណៈ ។ គណនេយ្យករសាធារណៈនេះ រ៉ាប់រងលើការត្រួតពិនិត្យចលនាបៀវត្ស តាមរយៈលិខិតបញ្ជាក់នានា ។ បន្ទាប់មក ក្រោយពីការរៀបចំនូវតារាងទូទាត់បៀវត្សរួចហើយ ត្រូវបញ្ជូននូវតារាងទូទាត់បៀវត្សទាំងនោះទៅតាមអង្គភាពបុគ្គលិកនីមួយៗ ដែលមានការពាក់ព័ន្ធ ។ អាណត្តិនិយតកម្មត្រូវធ្វើឡើងដោយអាណាប័ក ឬប្រធានគ[illegible]ដំណាលគ្នា នឹងតារាងទូទាត់បៀវត្ស ព្រមទាំងមានទិដ្ឋាការរបស់អភិបាលហិរញ្ញវត្ថុផង ។ ការបើកប្រាក់ធ្វើឡើងដោយភ្នាក់ងារបើកផ្តល់ក្រោមការត្រួតពិនិត្យរបស់រតនាគារ។

មាត្រា ៤ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវកំណត់នូវទំរង់បែបបទ និងការណែនាំអនុវត្តដោយលំអិតនូវអនុក្រឹត្យនេះ ស្តីពីនីតិវិធីសំរាប់អនុវត្តចំពោះលិខិតបទដ្ឋានឯកត្តជនក្នុងការគ្រប់គ្រងតាមប្រភេទនីមួយៗ ។

ជំពូក២

វិធានការអន្តរកាល

មាត្រា ៥ : ក្នុងរយៈពេលសាកល្បងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមប្រព័ន្ធកុំព្យូទ័រ ហើយក្នុងករណីដែលការប្រើប្រាស់នេះពុំទាន់សំរេចជាស្ថាពរ ការប្រើប្រាស់នូវប្រព័ន្ធប្រើដោយដៃបច្ចុប្បន្ននៅជាធរមាននៅឡើយ ។

មាត្រា ៦ : ក្នុងជំហានដំបូងនៃការប្រើប្រាស់សំភារៈទំនើបនេះ ប្រព័ន្ធថ្មីនៃការគ្រប់គ្រងត្រូវដាក់អោយដំណើរការតាមក្រសួង ដែលបានបំពាក់សំភារៈរួចហើយ ។ ចំពោះក្រសួងដែលពុំទាន់មានបណ្តាញម៉ាស៊ីនកុំព្យូទ័រក្នុងអង្គភាពគ្រប់គ្រងរបស់ខ្លួន ក្រសួងអាចធ្វើទំនាក់ទំនងផ្ទាល់ ដើម្បីប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៧ : នីតិវិធីនៃការគ្រប់គ្រងមន្ត្រីរាជការ នឹងចូលជាធរមាន សំរាប់ក្រសួង និងស្ថាប័ននីមួយៗ លុះត្រាតែក្រសួងនិងស្ថាប័នទាំងនោះបានធ្វើសុពលភាពលើពតិមាន

ទាំងឡាយដែលមាននៅក្នុងមូលដ្ឋានទិន្នន័យពត៌មានវិទ្យារួចក្រោមការត្រួតពិនិត្យ និងការណែនាំពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

មាត្រា ៨ : បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ ព្រះហស្តលេខា និងត្រា **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២ ហត្ថលេខា និងត្រា **ហ៊ុន សែន**

សូមបង្គំទូលថ្វាយ និងជំរាបជូនៈ

–សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

–សម្តេចនាយករដ្ឋមន្ត្រីទី២

រដ្ឋលេខាធិការនៃ
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
ធ្លាក់ សុខ

* * * *

II- ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣៩១ ប្រក.សហវ.ពដ

ស្ដីពី

អាករពិសេសលើទំនិញនិងសេវាមួយចំនួន

******

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២–នស–៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត–១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស–រកត–១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស–រកម–០១៩៦–១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្ដីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២–នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ស្ដី

...កែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨-នស-៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស-រកម-០៩៩៥-០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម- ០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- បានឃើញប្រកាសលេខ ០៦៧-សហវ-ប្រក-គរ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧ ស្តីពីការណែនាំអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធចំពោះអាករពិសេសលើទំនិញសេវាមួយចំនួន សំរាប់ទំនិញ នាំចូល ។

សំរេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

ផ្នែកទី១.១.—មូលដ្ឋានគិតអាករ

១- អាករពិសេសលើទំនិញនិងសេវាមួយចំនួន ហៅកាត់ថា អពទស ត្រូវអនុវត្តលើមុខទំនិញទាំងឡាយ ដូចមានចែងក្នុងមាត្រា១៨ និងមាត្រា១៩ នៃច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីសារពើពន្ធ ទោះបីជាទំនិញទាំងនោះជាទំនិញនាំចូល ឬ ជា ទំនិញផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្តី ។

២- អពទស ត្រូវអនុវត្តលើសេវាដូចខាងក្រោម ដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាៈ

- ការផ្តត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសពីចំណុចមួយ នៅក្នុ ព្រះរាជាណាចក្រកម្ពុជា ទៅកំណុចមួយនៅខាងក្រៅព្រះរាជាណាចក្រកម្ពុជា តា ជើងហោះហើរ[illegible] ឬមិនទៀងទាត់របស់សហគ្រាសអាកាសចរ ។ អពទស មិនត្រូវអនុវត្តទេលើការហោះហើរក្នុង ចំណែកណាមួយដែលមានចំណុចចេញ ដំណើរ និងចំណុចទៅដល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលគ្មានកា ចុះសំចតក្នុងចន្លោះទាំងពីរនេះ ។
- ការផ្គត់ផ្គង់សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ។
- ការផ្គត់ផ្គង់បន្ទប់សណ្ឋាគារ និងសេវាលំហែកំសាន្តផ្សេងៗនៅក្នុងព្រះរាជាណា ចក្រកម្ពុជា ។

ផ្នែកទី១.២.—អត្រាអាករ

អត្រា អពទស ត្រូវបានកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ភ្ជាប់ជាមួយ ប្រកាសនេះ ។

ជំពូកទី២

ភារកិច្ចរបស់បុគ្គលចុះបញ្ជីនិងអ្នកនាំចូលទំនិញជាប់អាករ

ផ្នែកទី២.១.—អ្នកនាំចូល

១– អ្នកនាំចូល គឺជាបុគ្គលិកបានចុះបញ្ជីដែលបាននាំចូលទំនិញជាប់អាករ ឬ រូបវន្តបុគ្គលមិនបានចុះបញ្ជីដែលបាននាំចូលទំនិញលើសពីចំនួនត្រូវរួចគយដូច មានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ។

២– អ្នកនាំចូលត្រូវបង់ អពទស លើទំនិញនាំចូលដោយផ្អែកលើតម្លៃក្នុងគយបូក បន្ថែមពន្ធ និង អាករដែលបង់នាពេលនាំចូល លើកលែងតែ អពទស ខ្លួនឯង និង អាករប្រើប្រាស់ដែលត្រូវបង់នាពេលនាំចូលនៅមុនពេលយកទំនិញចេញពី ការឃុំគ្រងរបស់ទីចាត់ការគយ និងរដ្ឋាករ ។

ផ្នែកទី២.២.—ផលិតករក្នុងស្រុក

១– ផលិតករក្នុងស្រុកដែលផលិតទំនិញជាប់ អពទស ត្រូវប្រមូល អពទស នៅ

ពេលធ្វើការផ្គត់ផ្គង់ទំនិញជាប់អាករ ដោយផ្អែកលើថ្លៃលក់ចេញពីរោងចក្រកត់ត្រាក្នុងវិក្កយបត្រ ។

ផ្នែកទី២.៣.– អ្នកផ្គត់ផ្គង់សេវា

១– ចំពោះការដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាស ក្រៅពីការលើកលែងដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃផ្នែកទី១.១ នៃប្រកាសនេះ អពទស ត្រូវប្រមូលលើមូលដ្ឋានតម្លៃដែលមាននៅក្នុងសំបុត្រយន្តហោះនានាដែលបានចេញ ឬ បានលក់អោយអ្នកដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះសំបុត្រយន្តហោះទៅ–មកសំរាប់ការធ្វើដំណើរចេញពីព្រះរាជាណាចក្រកម្ពុជា និងត្រឡប់មកដល់ព្រះរាជាណាចក្រកម្ពុជាវិញ អពទស ត្រូវប្រមូលលើ ៥០% នៃមូលដ្ឋានតម្លៃនៃសំបុត្រយន្តហោះទាំងនោះ ។

២– សំរាប់គោលដៅនៃ អពទស មូលដ្ឋានតម្លៃ គឺជាតម្លៃបូកត្រួតគ្នានៃគូប៉ុងទាំងអស់ ដូចមានកត់ត្រានៅលើបន្ទាត់គណនាតម្លៃនៃសំបុត្រយន្តហោះនានា ។

៣– សំបុត្រយន្តហោះនានា ត្រូវចាត់ទុកថាបានចេញ ឬ លក់អោយអ្នកដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើសិនជាសំបុត្រយន្តហោះទាំងនោះ ត្រូវបានប្រគល់អោយអ្នកដំណើរមុនពេលចេញដំណើរពីព្រះរាជាណាចក្រកម្ពុជា ហើយការហោះហើរដែលមានចុះក្នុងសំបុត្រយន្តហោះតួបគ្នាទាំងអស់ បូករួមទាំងការឈប់សំចតផង ផ្តិបានជាការធ្វើដំណើរមួយជើងបាន ។

៤– បុគ្គលដែលត្រូវប្រមូល និងបង់ អពទស លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសជូនរដ្ឋ គឺជាអ្នកចេញសំបុត្រយន្តហោះ បើសិនជាសំបុត្រយន្តហោះទាំងនោះ ត្រូវបានចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ចំពោះសហគ្រាសអាកាសចរដែលចេញសំបុត្រយន្តហោះនៅបរទេស ប៉ុន្តែបញ្ជូនសំបុត្រយន្តហោះមកព្រះរាជាណាចក្រកម្ពុជាដើម្បីលក់ សហគ្រាសនោះត្រូវធ្វើអាជីវកម្មរបស់ខ្លួនតាមរយៈទីភ្នាក់ងារមានការអនុញ្ញាតមួយ ដែលបានចុះបញ្ជីត្រឹមត្រូវធ្វើក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីនេះ ទីភ្នាក់ងារមានការអនុញ្ញាត គឺជាអ្នកត្រូវប្រមូល និងបង់ អពទស ជូនរដ្ឋ ។ សំបុត្រយន្តហោះដែលបានចេញ

នៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈពេញលេញស្របតាមការតម្រូវនានាចំពោះវិក្កយបត្រ ដូចមានចែងក្នុងកថាខ័ណ្ឌ នៃផ្នែកទី៤.៧ នៃប្រកាសនេះ ហើយទីភ្នាក់ងារមានការអនុញ្ញាតក៏ត្រូវប្រតិបត្តិតាមការតម្រូវនានាខាងការកត់ត្រាគណនេយ្យ ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃផ្នែកទី៤.៣ នៃប្រកាសនេះដែរ ។

៥– ចំពោះសេវាទូរគមនាគមន៍អន្តរជាតិ អ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍ត្រូវប្រមូល អាករ លើតម្លៃសេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ហើយនិងកំរៃជាប់ទាក់ទិនផ្សេងៗទៀត នៅពេលចេញវិក្កយបត្រទៅអោយអ្នកប្រើប្រាស់ ។

៦– ចំពោះបន្ទប់សណ្ឋាគារ អ្នកផ្គត់ផ្គង់បន្ទប់សណ្ឋាគារត្រូវប្រមូល អាករ លើកំរៃបន្ទប់សណ្ឋាគារដោយមិនគិតបញ្ចូលនូវកំរៃសេវា និងប្រាក់អាករលើផលរបរនៅពេលចេញវិក្កយបត្រ ។

ផ្នែកទី២.៤.— ការផ្គត់ផ្គង់អោយខ្លួនឯង

១– ផលិតករក្នុងស្រុក ឬ អ្នកនាំចូលទំនិញជាប់ អាករ ឬ អ្នកផ្គត់ផ្គង់សេវាជាប់ អាករ ដែលបានដកយកទំនិញ ឬសេវាទាំងនោះសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ការប្រើប្រាស់របស់បុគ្គលិក ឬ គតិយជន តាមការផ្តល់ជាអំណោយ ឬ ការលក់ក្រោមតម្លៃទីផ្សារត្រូវបង់ អាករ លើទំនិញ ឬ សេវាតាមតម្លៃទីផ្សារនៅពេលដកយកទំនិញ ឬ សេវាទាំងនោះ ។

ជំពូកទី៣

ការចុះបញ្ជីបុគ្គលជាប់ អាករ

៣.១.—អ្នកនាំចូលទំនិញជាប់ អាករ

១– បុគ្គលដែលបាននាំចូលទំនិញជាប់អាករតាមបទបញ្ញត្តិស្តីពី អាករ សំរាប់លក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ សំរាប់នាំចេញទៅវិញ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មធម្មតារបស់ខ្លួន ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារជាមុន

ទើបអាចបានទទួលបុព្វសិទ្ធិនាំចូលទំនិញមកក្នុង ឬ នាំចេញទំនិញអំពីព្រះរាជាណាចក្រកម្ពុជា ។

២- វិធានចុះបញ្ជីនេះ មិនត្រូវអនុវត្តទេ ចំពោះរូបវន្តបុគ្គលដែលនាំចូលទំនិញសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ។ រូបវន្តបុគ្គលអ្នកនាំចូលទំនិញសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ដែលគ្មានកាតព្វកិច្ចចុះបញ្ជីនេះ មិនត្រូវបានលើកលែងទេ អំពីកាតព្វកិច្ចបង់ប្រាក់អាករលើទំនិញជាប់ អពទ៧ ។

វគ្គកទី៣.២:— ផលិតករក្នុងស្រុកដែលផលិតទំនិញជាប់ អពទស

១- ផលិតករក្នុងស្រុកដែលផលិតទំនិញជាប់ អពទស ទោះបីសំរាប់លក់ក្នុងស្រុក ឬ សំរាប់នាំចេញក្តី ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ យ៉ាងយឺតបំផុត១៥ថ្ងៃ ក្រោយពេលចាប់ផ្តើមផលិតទំនិញទាំងនោះ ។

២- បទបញ្ញត្តិអន្តរកាលសំរាប់ផលិតករបច្ចុប្បន្នដែលផលិតទំនិញជាប់ អពទស មានចែងក្នុងជំពូក ទី៩ នៃប្រកាសនេះ ។

វគ្គកទី៣.៣:—អ្នកផ្គត់ផ្គង់សេវាជាប់ អពទស

១- សហគ្រាសអាកាសចរ ឬ ទីភ្នាក់ងារមានការអនុញ្ញាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់សហគ្រាសអាកាសចរ អនិវាសនជនដែលបានទទួលការអនុញ្ញាតិអោយចេញ ឬ លក់សំបុត្រយន្តហោះក្នុងនាម សហគ្រាសអាកាសចរ អនិវាសនជនអោយអ្នកដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុត១៥ថ្ងៃក្រោយពេលចាប់ផ្តើមប្រតិបត្តិការ ។

២- អ្នកផ្គត់ផ្គង់ក្នុងស្រុកនូវសេវាទូរគមនាគមន៍អន្តរជាតិ ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ យ៉ាងយឺតបំផុត១៥ថ្ងៃក្រោយពេលចាប់ផ្តើមផ្គត់ផ្គង់សេវា ។

៣- អ្នកផ្គត់ផ្គង់បន្ទប់សណ្ឋាគារ ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារ យ៉ាងយឺតបំផុត ១៥ថ្ងៃ ក្រោយពេលចាប់ផ្តើមការផ្គត់ផ្គង់នេះ ។

៤- បទបញ្ញត្តិអន្តរកាលសំរាប់អ្នកផ្គត់ផ្គង់បច្ចុប្បន្ន នូវសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ សេវាទូរគមនាគមន៍អន្តរជាតិ និងបន្ទប់សណ្ឋាគារ មានចែងនៅក្នុងជំពូកទី៩ នៃប្រកាសនេះ ។

ជំពូកទី៤

ការតម្រូវនានាចំពោះការកត់ត្រាគណនេយ្យ

ផ្នែកទី៤.១.—ការតំរូវចំពោះទំនិញនាំចូល

១– ចំពោះការនាំចូលទំនិញមកក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាសំរាប់ការប្រើប្រាស់ក្នុងស្រុក ឬ សំរាប់ការនាំចេញទៅវិញ និង ទោះបីជាទំនិញទាំងនោះត្រូវបានដឹកមកពីប្រទេសណាក៏ដោយ អ្នកនាំចូលត្រូវកាន់កាប់បញ្ជីនាំចូលប្រចាំថ្ងៃសំរាប់ចុះនូវពត៌មានដូចតទៅនេះ ទាក់ទិននឹងការនាំចូលនីមួយៗ :

– លេខ និង កាលបរិច្ឆេទប្រតិវេទន៍គយសំរាប់ការនាំចូល ឈ្មោះអង្គភាពគយដែលបានពិនិត្យ អនុញ្ញាតអោយទំនិញចូល និងកាលបរិច្ឆេទយកទំនិញចេញអំពីការឃុំគ្រងរបស់គយ ដើម្បីនាំចូល មកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា

– បរិមាណ គុណភាព ទម្ងន់ លេខសេរី បើសិនជាមាន និងបរិយាយមុខទំនិញនាំចូលតាមលេខ សំគាល់គយ និងតាមម៉ាក

– តម្លៃឯកតា និងតម្លៃសរុបរបស់ទំនិញនាំចូល ពត៌មានសង្ខេបអំពីតម្លៃសរុបរបស់ទំនិញនាំចូលក្នុងនោះមានថ្លៃដើមទំនិញ និងសង្ខេបអំពីតម្លៃផ្សេងៗទៀតដែលជាចំណែកនៃតម្លៃសរុបរបស់ទំនិញ នាំចូល

– ចំនួនប្រាក់ពន្ធគយដែលបានបង់

– ចំនួនប្រាក់ អពទស ដែលបានបង់

– កាលបរិច្ឆេទ និង លេខបង្កាន់ដៃបង់ពន្ធ

– កាលបរិច្ឆេទទំនិញនាំចូលត្រូវបានដឹកចូលឃ្លាំងអ្នកនាំចូល និង

– បរិមាណទំនិញតាមលេខសំគាល់គយ និងតាមម៉ាក ដែលបាននាំចូលសំរាប់នាំចេញទៅវិញ ។

២– អ្នកនាំចូលទំនិញជាប់ អពទស ត្រូវបញ្ចូលទំនិញទៅក្នុងឃ្លាំងស្តុកទំនិញជាប់ អពទស នឹងត្រូវមានបញ្ជីឃ្លាំងកត់ត្រាតាមដានប្រចាំថ្ងៃនូវពត៌មានដូចតទៅ :

- បរិមាណទំនិញនាំចូលតាមលេខសំគាល់គយ និង តាមម៉ាក សំរាប់ការប្រើប្រាស់ក្នុងស្រុក ដែលបានបញ្ចូលឃ្លាំងនៅក្នុងថ្ងៃនេះ
- បរិមាណទំនិញនាំចូលតាមលេខសំគាល់គយ និងតាមម៉ាក សំរាប់ការនាំចេញទៅវិញ ដែលបានបញ្ចូលឃ្លាំងនៅក្នុងថ្ងៃនេះ
- បរិមាណ និង តម្លៃឯកតាទំនិញនាំចូលតាមលេខសំគាល់គយ និង តាមម៉ាក ដែលបានបញ្ចេញពីស្តុកនៅក្នុងថ្ងៃនេះ ដើម្បីយកទៅលក់សំរាប់ការប្រើប្រាស់ក្នុងស្រុក
- បរិមាណ និងតម្លៃឯកតាទំនិញនាំចូលតាមលេខសំគាល់គយ និងតាមម៉ាក ដែលបានបញ្ចេញពីស្តុកនៅក្នុងថ្ងៃនេះ ដើម្បីនាំចេញទៅវិញ
- ស្ថានភាពទំនិញនាំចូលតាមលេខសំគាល់គយ និងតាមម៉ាក ដែលមាននៅក្នុងស្តុកនៅពេលបិទម៉ោងធ្វើការក្នុងថ្ងៃនេះ ។

៣- អ្នកនាំចូលទំនិញជាប់ អពទស ត្រូវកាន់កាប់ទិន្នានុប្បវត្តិលក់ប្រចាំថ្ងៃ និងត្រូវកត់ត្រានូវពត៌មាន ដូចខាងក្រោមនៅពេលធ្វើការផ្គត់ផ្គង់ :

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខរៀងវិក្កយបត្រ
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកទិញ ហើយនិងលេខអត្តសញ្ញាណកម្ម សារពើពន្ធរបស់អ្នកទិញ បើសិនជាមាន
- សេចក្តីបរិយាយអំពីទំនិញលក់ចេញតាមលេខសំគាល់គយ និង តាមម៉ាក
- តម្លៃឯកតា និង តម្លៃសរុបរបស់ទំនិញលក់ចេញ
- ចំនួនប្រាក់អាករលើផលរបរត្រូវប្រមូល និង
- ការបរិច្ឆេទបញ្ជូនទំនិញបើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ ។

៤- បញ្ជីនាំចូល បញ្ជីឃ្លាំង និង ទិន្នានុប្បវត្តិលក់ ដែលអ្នកនាំចូលទំនិញជាប់ អពទស ត្រូវកាន់កាប់ ត្រូវធ្វើតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និងចុះហត្ថលេខាបញ្ជាក់ជាមុន ដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិប្រទាន ។

ផ្នែកទី៤.២:— ការតំរូវសំរាប់ទំនិញផលិតក្នុងស្រុក

១– ចំពោះសំភារៈធាតុចូល សំរាប់ប្រើប្រាស់ក្នុងការផលិតទំនិញជាប់ អពទស ផលិតករត្រូវកាន់កាប់បញ្ជីប្រចាំថ្ងៃសំរាប់សំភារៈប្រើប្រាស់ទាំងនោះ និងត្រូវកត់ត្រានូវពត៌មានដូចតទៅ :

– បរិមាណតាមប្រភេទសំភារៈធាតុចូល ដែលបានបញ្ចូលស្តុក និង

– បរិមាណតាមប្រភេទសំភារៈធាតុចូល ដែលបានបញ្ចេញពីស្តុក ហើយនិងមុខសញ្ញាប្រើប្រាស់ របស់សំភារៈធាតុចូល ដែលបានបញ្ចេញនោះ

– ស្ថានភាពតាមប្រភេទសំភារៈធាតុចូល ដែលមាននៅក្នុងស្តុក នៅពេលចប់ម៉ោងធ្វើការក្នុងថ្ងៃនេះ។

២– ចំពោះទំនិញជាប់ អពទស ដែលផលិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាផលិតករត្រូវកាន់កាប់បញ្ជីផលិត និងបញ្ចូលបញ្ចេញឃ្លាំងប្រចាំថ្ងៃ និងត្រូវកត់ត្រាពត៌មានដូចតទៅ :

– បរិមាណទំនិញផលិតបានតាមលេខសំគាល់គយ និងតាមម៉ាក

– បរិមាណ និងថ្លៃឯកតាតាមលេខសំគាល់គយ និងតាមម៉ាកនៃទំនិញបញ្ចេញពីស្តុក ដើម្បីយក ទៅលក់សំរាប់ការប្រើប្រាស់ក្នុងស្រុក ឬ ដើម្បីនាំចេញ ។

– ស្ថានភាពទំនិញក្នុងស្តុកតាមលេខសំគាល់គយ និងតាមម៉ាក នៅពេលចប់ម៉ោងធ្វើការក្នុងថ្ងៃនេះ

៣– ផលិតករទំនិញជាប់ អពទស ត្រូវកាន់កាប់ទិន្នានុប្បវត្តិលក់ប្រចាំថ្ងៃ ដែលក្នុងនោះត្រូវកត់ត្រា នៅពេលផ្គត់ផ្គង់នូវពត៌មានដូចតទៅ :

– កាលបរិច្ឆេទចេញវិក្កយបត្រ

– លេខរៀងវិក្កយបត្រ

– ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកទិញ ហើយនិងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើសិនជាមាន

– សេចក្តីបរិយាយអំពីទំនិញលក់ចេញតាមលេខសំគាល់គយ និងតាមម៉ាក

- តម្លៃឯកតាចេញពីរោងចក្រ និងតម្លៃសរុបចេញពីរោងចក្ររបស់ទំនិញលក់ចេញគ្មាន អពទស
- ចំនួនប្រាក់ អពទស ត្រូវប្រមូល
- តម្លៃមាន អពទស នៃទំនិញលក់ចេញ
- បន្ទុកផ្សេងៗទៀតដែលជាប់ទាក់ទិននឹងការលក់ទំនិញ
- ចំនួនប្រាក់អាករលើផលរបរ ត្រូវប្រមូល
- តម្លៃមានអាករនៃទំនិញលក់ចេញ និង
- កាលបរិច្ឆេទបញ្ជូនទំនិញបើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ ។

៤- បញ្ជីសំភារៈធាតុចូល បញ្ជីផលិតនិងបញ្ចូលបញ្ចេញឃ្លាំង និងទិនានុប្បវត្តិលក់ត្រូវធ្វើតាម ទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និង ចុះហត្ថលេខាបញ្ជាក់ជាមុន ដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិប្រទាន ។

ផ្នែកទី៤.៣.— ការតម្រូវចំពោះអ្នកផ្គត់ផ្គង់សេវាដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ

១- បុគ្គលជាប់ អពទស សំរាប់ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិត្រូវកាន់កាប់បញ្ជីស្តុកប្រចាំថ្ងៃនៃសំបុត្រយន្តហោះទាំងអស់ដែលខ្លួនបានទទួល ដោយត្រូវកត់ត្រានូវពត៌មានដូចតទៅ :

- កាលបរិច្ឆេទទទួលសំបុត្រយន្តហោះ
- សំរាប់សំបុត្រយន្តហោះមួយដុំៗ ត្រូវកត់ត្រាលេខរៀងសំបុត្រនានាដែលបានទទួល និង
- កាលបរិច្ឆេទ និង លេខរៀងសំបុត្រយន្តហោះដែលបានដកពីក្នុងស្តុកដើម្បីចេញ ឬ លក់អោយ អ្នកដំណើរ ។

២- ចំពោះការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ បុគ្គលជាប់ អពទស ត្រូវកាន់កាប់ ទិន្នានុប្បវត្តិលក់ប្រចាំថ្ងៃ សំរាប់សំបុត្រយន្តហោះដែលបានចេញ ឬ លក់ ។ នៅពេលផ្គត់ផ្គង់បុគ្គលនោះ ត្រូវកត់ត្រានូវពត៌មានដូចខាងក្រោមសំរាប់សំបុត្រយន្តហោះនីមួយៗ :

- កាលបរិច្ឆេទចេញ ឬ លក់សំបុត្រយន្តហោះ
- លេខរៀងសំបុត្រយន្តហោះ និងចំនួនគូប៉ុងដែលភ្ជាប់ជាមួយសំបុត្រយន្តហោះ
- ឈ្មោះអ្នកដំណើរដែលសហគ្រាសបានចេញ ឬ លក់សំបុត្រយន្តហោះអោយដូចមានចុះនៅក្នុង សំបុត្រយន្តហោះ
- ចំណុចចេញដំណើរ និងចំណុចទៅដល់នៃគូប៉ុងនីមួយៗ ដែលភ្ជាប់ជាមួយសំបុត្រយន្តហោះ ។ បើមានគូប៉ុងណាមួយមិនប្រើការ ត្រូវចុះបញ្ជាក់នៅក្នុងបញ្ជីថាជាគូប៉ុងមោឃៈ
- មូលដ្ឋានតម្លៃរបស់គូប៉ុងនីមួយៗដែលភ្ជាប់ជាមួយសំបុត្រយន្តហោះ ក្នុងនោះមានទាំងមូលដ្ឋានតម្លៃរបស់គូប៉ុងនីមួយៗ ដែលមានចំណុចចេញដំណើរ និងចំណុចទៅដល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- តម្លៃសំបុត្រយន្តហោះ ដូចមានកត់ត្រានៅលើបន្ទាត់តម្លៃនៃសំបុត្រយន្តហោះ
- ចំនួនប្រាក់ អពទស ត្រូវប្រមូល និង
- ចំនួនប្រាក់អាករលើផលរបរត្រូវប្រមូល បើសិនជាមាន ។

៣– បញ្ជីស្តុកសំបុត្រយន្តហោះ និងវិក្កយបត្រលក់សំបុត្រយន្តហោះ ត្រូវធ្វើតាមទំរង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និងចុះហត្ថលេខាបញ្ជាក់ជាមុន ដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិប្រទាន ។

ផ្នែកទី៤.៤:— ការតម្រូវចំពោះអ្នកផ្គត់ផ្គង់សេវាទូរគមនាគមន៍អន្តរជាតិ

១– សំរាប់ការផ្គត់ផ្គង់សេវាទូរគមនាគមន៍អន្តរជាតិ បុគ្គលជាប់ អពទស ត្រូវកាន់កាប់វិក្កយបត្រ វិក្កយបត្រចេញប្រចាំថ្ងៃ ដោយក្នុងនោះត្រូវកត់ត្រានៅពេលផ្គត់ផ្គង់នូវពត៌មានដូចខាងក្រោមសំរាប់អ្នកជាវម្នាក់ៗ:

- ទឹកប្រាក់សេវាបានផ្គត់ផ្គង់ដែលត្រូវកត់ត្រាក្នុងវិក្កយបត្រ ក្នុងនោះមានទាំងចំណាយតាមចំនួននាទីប្រើប្រាស់ និងកម្រៃជាប់ទាក់ទិនផ្សេងទៀតនៃវិក្កយបត្រដែលត្រូវចេញនោះ

- ទឹកប្រាក់សេវាផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវកត់ត្រាក្នុងវិក្កយ-បត្រ ក្នុងនោះមានទាំងចំណាយតាមចំនួននាទីប្រើប្រាស់ និងកម្រៃជាប់ទាក់ទិនផ្សេងទៀត
- ទឹកប្រាក់សេវាបានផ្គត់ផ្គង់សំរាប់សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ក្នុងនោះមានទាំងចំណាយតាមចំនួននាទីប្រើប្រាស់ និងកម្រៃជាប់ទាក់ទិនផ្សេងទៀត
- ប្រាក់ អពទស ត្រូវប្រមូល និង
- ចំនួនប្រាក់អាករលើផលរបរ ត្រូវប្រមូល ។

២- ទិន្នានុប្បវត្តិនេះ ត្រូវធ្វើតាមទំរង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និងចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិប្រទាន ។

ផ្នែកទី៤.៥:— បន្ទប់សណ្ឋាគារ

១- ចំពោះការផ្គត់ផ្គង់បន្ទប់សណ្ឋាគារ បុគ្គលជាប់ អពទស ត្រូវកាន់កាប់ទិន្នានុប្បវត្តិវិក្កយបត្រ ចេញប្រចាំថ្ងៃ ដោយត្រូវកត់ត្រានៅពេលផ្គត់ផ្គង់ នូវពត៌មានដូចខាងក្រោម លើការផ្គត់ផ្គង់នីមួយៗ

- ថ្លៃបន្ទប់សរុបត្រូវកត់ត្រាក្នុងវិក្កយបត្រដែលត្រូវចេញ
- ប្រាក់ អពទស ត្រូវប្រមូល
- ថ្លៃសរុបមាន អពទស
- ប្រាក់ចំណូលផ្សេងៗ ក្រៅពីថ្លៃបន្ទប់
- ប្រាក់អាករលើផលរបរត្រូវប្រមូល
- ថ្លៃសរុបមាន អពទស និងអាករលើផលរបរ

២- ទិន្នានុប្បវត្តិត្រូវធ្វើតាមទំរង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និង ចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិប្រទាន ។

ផ្នែកទី៤.៦:— ពេលផ្គត់ផ្គង់

១– ពេលផ្គត់ផ្គង់ ឬ ពេលដកយកទំនិញ ឬ សេវា គឺជាពេលដែលបុគ្គលនោះត្រូវចេញវិក្កយបត្រ ឬ ជាពេលដែលបុគ្គលនោះបានចេញវិក្កយបត្រ បើសិនជាវិក្កយបត្រត្រូវបានចេញមុនពេលដែលបុគ្គលត្រូវ ចេញវិក្កយបត្រ ។

២– ពេលដែលបុគ្គលជាប់អាករត្រូវចេញវិក្កយបត្រ គឺមិនត្រូវយឺតជាង ៧ ថ្ងៃ :

– ក្រោយការបំពេញសេវារួច ឬ ការបញ្ជូនទំនិញ

– ក្រោយការទូទាត់ បើសិនជាការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញ ឬការបំពេញសេវា ។

៣– ការបញ្ជូនទំនិញត្រូវមានវិក្កយបត្រភ្ជាប់តាមជានិច្ច បើសិនជាមានចេញវិក្កយបត្រហើយលើទំនិញបញ្ជូនចេញ ។ បើសិនជានៅពេលបញ្ជូនទំនិញមិនទាន់មានចេញវិក្កយបត្រទេ ការបញ្ជូនទំនិញត្រូវមាន ភ្ជាប់ឯកសារបញ្ជូនទំនិញ ដែលបានកត់ត្រាត្រឹមត្រូវក្នុងទិន្នានុប្បវត្តិបញ្ជូនទំនិញរបស់អ្នកលក់ទំនិញ ។

៤– ពេលផ្គត់ផ្គង់សំរាប់សំបុត្រយន្តហោះ គឺជាពេលដែលបុគ្គលជាប់អាករចេញសំបុត្រយន្តហោះ ។ ចំពោះទីភ្នាក់ងារមានការអនុញ្ញាត ដែលបាននាំចូលសំបុត្រយន្តហោះ ដែលបានចេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា សំរាប់លក់ទៅអោយបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពេលផ្គត់ផ្គង់គឺជាពេលដែលទីភ្នាក់ងារមានការអនុញ្ញាតលក់សំបុត្រយន្តហោះ ទៅអោយអ្នកដំណើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥– ពេលផ្គត់ផ្គង់សំរាប់សេវាទូរគមនាគមន៍ ឬ បន្ទប់សណ្ឋាគារ គឺជាពេលដែលបុគ្គលជាប់អាករ ចេញវិក្កយបត្រសំរាប់សេវាទូរគមនាគមន៍ ឬ បន្ទប់សណ្ឋាគារដែលបានផ្គត់ផ្គង់ ។

ផ្នែកទី៤.៧:— វិក្កយបត្រ

១– អ្នកនាំចូលដែលលក់ទំនិញនាំចូលជាប់ អពទស សំរាប់ការប្រើប្រាស់ក្នុងស្រុក ឬ សំរាប់ការនាំចេញ ត្រូវចេញវិក្កយបត្រមានលេខរៀង ដែលមានចុះពត៌មានដូចតទៅ :

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកលក់
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកទិញ និង លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើ សិនជាមាន
- ទីតាំងនៃឃ្លាំង ដែលទំនិញត្រូវបានបញ្ជូនចេញ បើសិនជាខុសគ្នាពីអាស័យដ្ឋានរបស់អ្នកលក់
- បរិមាណ និង បរិយាយមុខទំនិញដែលបានលក់ចេញតាមលេខសំគាល់គយ និង តាមម៉ាក
- តម្លៃឯកតា និងតម្លៃសរុបរបស់ទំនិញលក់ចេញ
- ប្រាក់អាករលើផលរបរដែលត្រូវប្រមូល បើសិនជាទំនិញសំរាប់ការដាក់លក់ក្នុងស្រុក និង
- ក្នុងករណីដែលទំនិញមានរាយលំអិត ត្រូវបានលក់សំរាប់ការនាំចេញ ត្រូវមានចុះបញ្ជាក់ថា«ទំនិញរាយលំអិតទាំងនេះ សំរាប់នាំចេញពីព្រះរាជាណាចក្រកម្ពុជា»។

២– ផលិតករក្នុងស្រុកដែលលក់ទំនិញផលិតក្នុងស្រុកជាប់ អពទស សំរាប់ការប្រើប្រាស់ក្នុងស្រុក ឬ សំរាប់ការនាំចេញ ត្រូវចេញវិក្កយបត្រមានលេខរៀង ដែលមានចុះពត៌មានដូចតទៅ ៖

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកលក់
- ឈ្មោះ និង អាស័យដ្ឋានរបស់អ្នកទិញ និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើសិនជាមាន
- ទីតាំងនៃឃ្លាំងដែលទំនិញត្រូវបានបញ្ជូនចេញ បើសិនជាខុសគ្នាពីអាស័យដ្ឋានរបស់អ្នកលក់

- បរិមាណ និង បរិយាយមុខទំនិញដែលបានលក់ចេញតាមលេខសំគាល់គយ និង តាមម៉ាក
- តម្លៃឯកតាចេញពីរោងចក្រ និង តម្លៃសរុបចេញពីរោងចក្ររបស់ទំនិញលក់ចេញ
- ប្រាក់ អពទស ត្រូវប្រមូល
- តម្លៃមាន អពទស របស់ទំនិញលក់ចេញ បូកនឹងបន្ទុកផ្សេងទៀតដែលជាប់ទាក់ទិននឹងការលក់នោះ
- ប្រាក់អាករលើផលរបរត្រូវប្រមូល បើសិនជាទំនិញត្រូវបានលក់ សំរាប់ការដាក់លក់ក្នុងស្រុក
- ក្នុងករណីដែលទំនិញមានរាយលំអិត ត្រូវបានលក់សំរាប់ការនាំចេញ ត្រូវមានចុះបញ្ជាក់ថា«ទំនិញរាយលំអិតទាំងនេះ សំរាប់នាំចេញពីព្រះរាជាណាចក្រកម្ពុជា»។

៣– ចំពោះការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស សំបុត្រយន្តហោះរបស់អ្នកដំណើរ ដែលបុគ្គលចុះបញ្ជីត្រូវជាប់អាករបានចេញ ឬ លក់អោយ ត្រូវប្រើការជាវិក្កយបត្រពន្ធ ។ សំរាប់សំបុត្រយន្តហោះនីមួយៗ ដែលបានចេញ ឬ លក់អោយអ្នកដំណើរ មូលដ្ឋានតម្លៃ គឺជាតម្លៃរាយលំអិតនៅក្នុងតារាងតម្លៃ ដូចមានកត់ត្រា នៅលើបន្ទាត់តម្លៃនៃសំបុត្រយន្តហោះ ។ ប្រាក់ អពទស ឬ អាករលើផលរបរត្រូវបង់ ត្រូវកត់ត្រាដាច់ដោយឡែកពីគ្នា នៅលើបន្ទាត់នានាសំរាប់ពន្ធអាករនៃសំបុត្រយន្តហោះ ។ តម្លៃសរុបមាន អពទស និង អាករលើផលរបរត្រូវកត់ត្រានៅលើបន្ទាត់តម្លៃសរុបនៃសំបុត្រយន្តហោះរបស់អ្នកដំណើរ ។

៤– វិក្កយបត្រដែលសហគ្រាសទូរគមនាគមន៍ចេញអោយអ្នកជាវ បន្ថែមលើពត៌មានធម្មតាដែលត្រូវចុះ ត្រូវមានកត់ត្រាលើបន្ទាត់ផ្សេងពីគ្នានូវ :

- លេខរៀងរបស់វិក្កយបត្រ
- តម្លៃសេវាតាមចំនួននាទីប្រើប្រាស់ សំរាប់សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជា ទៅបរទេស និងកម្រៃជាប់ទាក់ទិនផ្សេងទៀត គ្មាន អពទស
- ប្រាក់ អពទស ត្រូវប្រមូល និង

- ប្រាក់អាករលើផលរបរត្រូវប្រមូល ។

៥- វិក្កយបត្រដែលអ្នកផ្គត់ផ្គង់បន្ទប់សណ្ឋាគារមានចេញអោយអតិថិជន បន្ថែមលើពត៌មានធម្មតា ដែលត្រូវចុះ ត្រូវមានកត់ត្រាលើបន្ទាត់ផ្សេងពីគ្នានូវ :

- លេខរៀងរបស់វិក្កយបត្រ
- ថ្ងៃបន្ទប់សណ្ឋាគារ គ្មាន អពទស
- ប្រាក់ អពទស ត្រូវប្រមូល និង
- ប្រាក់អាករលើផលរបរត្រូវប្រមូល ។

៦- លើកលែងតែទំនិញលក់ចេញសំរាប់ការនាំចេញ ឬ ការនាំចេញទៅវិញ វិក្កយបត្រដែលបាន ចែងក្នុងកថាខ័ណ្ឌ១ និងកថាខ័ណ្ឌ២ នៃផ្នែកនេះ ត្រូវចេញក្នុងរយៈពេលប្រាំពីរថ្ងៃក្រោយការបញ្ជូនទំនិញ ឬ ក្រោយការទូទាត់ ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញ ។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់មកជាមួយទេ ត្រូវមានភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិន្នានុប្បវត្តិបញ្ជូនទំនិញ ។

៧- សំរាប់ទំនិញដែលបានលក់ សំរាប់ការនាំចេញ ឬ ការនាំចេញទៅវិញ វិក័យប័ត្រត្រូវចេញនៅថ្ងៃបញ្ជូនទំនិញ ហើយត្រូវភ្ជាប់ជាមួយទំនិញក្នុងពេលត្រូវដឹកឆ្លងកាត់ ។

៨- អ្នកផ្គត់ផ្គង់ត្រូវរក្សាទុកវិក្កយបត្រដែលបានតម្រូវឡើងទាំងអស់ និង វិក្កយបត្រមោឃៈ តាមលំដាប់ថ្ងៃខែ និងនៅតាមទីកន្លែងដែលនាយកដ្ឋានពន្ធដារបានយល់ព្រម ។

៩- បើសិនជាត្រូវធ្វើការកែតម្រូវចំពោះវិក្កយបត្រណាមួយ ត្រូវភ្ជាប់ជាមួយ និង វិក្កយបត្រនោះ នូវ ច្បាប់ចម្លងឯកសារគណនេយ្យដែលកត់ត្រាការកែតម្រូវ ។

ផ្នែកទី៤.៨:—ការតម្រូវចំពោះការទុកដាក់ឯកសារ

១- បុគ្គលជាប់អាករត្រូវកាន់កាប់ និងរក្សាទុកបញ្ជីទិន្នានុប្បវត្តិ និងវិក្កយបត្រទាំងអស់នៅតាមទីកន្លែងដែលនាយកដ្ឋានពន្ធដារបានយល់ព្រមក្នុងរយៈពេល ១០ឆ្នាំ

ក្រោយកាលបរិច្ឆេទចេញវិក្កយបត្រ ឬ ក្រោយកាលបរិច្ឆេទនៃការកត់ត្រាចុងក្រោយបំផុតនៅលើបញ្ជី ឬ ទិន្នានុប្បវត្តិ ។

ជំពូកទី៥

វិធាននិងនីតិវិធីសំរាប់ទំនិញមួយចំនួន

ផ្នែកទី៥.១:— យានយន្ត

១– សំរាប់រថយន្តជាប់ អពទស ទីមួយៗ នៅពេលនាំចូលមកដល់ព្រះរាជាណាចក្រកម្ពុជា ត្រូវមានចុះពត៌មានដូចខាងក្រោមនៅក្នុងប្រតិវេទន៍គយសំរាប់ការនាំចូល :

– សេចក្តីបរិយាយសព្វគ្រប់អំពីរថយន្ត

– លេខអត្តសញ្ញាណកម្មរថយន្ត (VIN) និងលេខម៉ាស៊ីន ។ ត្រូវកត់ត្រាផងដែរនូវលេខតួ ឬ លេខសាក់ស៊ី សំរាប់គ្រប់ចំណែកនៃតួយាន ឬ សាក់ស៊ីដែលត្រូវបានផលិតដាច់ដោយឡែកពីគ្នា បើសិនជាមាន និង

– សំរាប់រថយន្តថ្មី ត្រូវកត់ត្រានូវលេខរៀងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម និងឈ្មោះក្រុមហ៊ុនផលិត ដូចមានចុះនៅក្នុងវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម និងសំរាប់រថយន្តប្រើហើយ ត្រូវកត់ត្រាលេខប័ណ្ណសំគាល់កម្មសិទ្ធិដែលប្រទេសនាំចេញបានចេញអោយ ។

២– សំរាប់រថយន្តនាំចូលនីមួយៗ ត្រូវមានចេញនូវបង្កាន់ដៃពន្ធនាំចូលមួយស្របតាមវិធាន និងនីតិវិធី ដូចតទៅ :

ក– បង្កាន់ដៃពន្ធនាំចូលសំរាប់របយន្ត ត្រូវធ្វើតាមទម្រង់មួយខុសគ្នាអំពីបង្កាន់ដៃពន្ធសំរាប់ទំនិញឯទៀត ។ ទម្រង់នេះត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ សំរាប់រថយន្តនីមួយៗ ដែលបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា:

– អង្គភាពគយដែលបានពិនិត្យអនុញ្ញាតអោយរថយន្តចូលត្រូវចេញបង្កាន់ដៃពន្ធនាំចូលដែលមាន ៥ច្បាប់

- ច្បាប់ទី១ ច្បាប់ទី២ និងច្បាប់ទី៣ ត្រូវបញ្ជូនទៅអោយទីចាត់ការគយ និងរដ្ឋាករ
- ច្បាប់ទី៤ ត្រូវប្រគល់អោយអ្នកនាំចូលភ្លាម
- ច្បាប់ទី៥ ត្រូវរក្សាទុកនៅក្នុងអង្គភាពគយអ្នកពិនិត្យអនុញ្ញាតអោយរថយន្តចូល

ខ- ក្រោយពេលទីចាត់ការគយ និងរដ្ឋាករបានពិនិត្យផ្ទៀងផ្ទាត់បង្កាន់ដៃពន្ធនាំចូលទាំងពាច្បាប់នេះ ហើយនាយកទីចាត់ការគយនិងរដ្ឋាករត្រូវចុះហត្ថលេខាបញ្ជាក់អំពីលក្ខណៈពិតប្រាកដ និង ត្រឹមត្រូវរបស់បង្កាន់ដៃពន្ធ នៅលើបង្កាន់ដៃពន្ធនាំចូលទាំងពាច្បាប់នេះ ។ ការផ្តល់សេចក្តីបញ្ជាក់នេះ ត្រូវកត់ត្រាតាមដាននៅក្នុងបញ្ជីមួយដាច់ដោយឡែក និងមានបង់លេខរៀង ហើយត្រូវកត់ត្រាលេខនេះនៅលើបង្កាន់ដៃពន្ធនាំចូលទាំងពាច្បាប់ផងដែរ ។

គ- ក្រោយពេលបានចុះសេចក្តីបញ្ជាក់ហើយ ទីចាត់ការគយ និងរដ្ឋាករត្រូវ :
- ប្រគល់ច្បាប់ទី១ និងច្បាប់ទី២ នៃបង្កាន់ដៃពន្ធនាំចូលទៅអោយនាំចូលនៅពេលបុគ្គលនេះ បង្ហាញច្បាប់ទី៤ នៃបង្កាន់ដៃពន្ធដែលទីចាត់ការគយ និងរដ្ឋាករត្រូវដកហូតទុកវិញ ។
- ប្រគល់ច្បាប់ទី៣ នៃបង្កាន់ដៃពន្ធនាំចូលអោយដល់នាយកដ្ឋានពន្ធដារក្នុងរយៈពេល១០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះហត្ថលេខាបញ្ជាក់អំពីលក្ខណៈពិតប្រាកដ និងត្រឹមត្រូវនៃបង្កាន់ដៃពន្ធរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

៤- កម្មសិទ្ធិករយានយន្តមានកាតព្វកិច្ចត្រូវបង់ អពទស លើយានយន្តនៅពេលចុះបញ្ជីសុំផ្លាកលេខ ឬ នៅពេលទិញប័ណ្ណបង់ពន្ធយានយន្តប្រចាំឆ្នាំបើសិនជា :
- កម្មសិទ្ធិមិនអាចបង្ហាញបង្កាន់ដៃពន្ធនាំចូល មានសុពលភាព
- កម្មសិទ្ធិករមិនអាចបង្ហាញភស្តុតាងច្បាស់លាស់ថា យានយន្តនោះបាននាំចូល ឬបានចុះបញ្ជី ធ្វើផ្លាកលេខ នៅមុនថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៧ ។

៥- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលភារៈគ្រប់គ្រងស្តុកបង្កាន់ដៃពន្ធនាំចូលសំរាប់រថយន្តដែលត្រូវចេញអោយទីចាត់ការគយ និង រដ្ឋាករតាមនីតិវិធីមួយដែលមានការត្រួតពិនិត្យស៊ីលាស់ ។

ជំពូកទី៦

ការគណនាប្រាក់អាករត្រូវបង់

ផ្នែកទី៦.១:— ការនាំចូល

១- ប្រាក់ អពទស ត្រូវគណនាតាមវិធាននិងនីតិវិធី ដូចមានចែងក្នុងប្រកាសលេខ ០៦៧-សហវ-ប្រក-គរ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ផ្នែកទី៦.២:— ផលិតករក្នុងស្រុក

១- នៅចុងខែនីមួយៗ ផលិករត្រូវគណនាសមតុល្យនៅក្នុងទិន្នានុប្បវត្តិលក់ ហើយត្រូវកត់ត្រាតម្លៃសរុបនៃទំនិញជាប់ អពទស ដែលបានលក់ចេញ និងប្រាក់ អពទស សរុបដែលបានប្រមូលនៅក្នុងខែនោះ ។

២- ប្រាក់ អពទស សរុបដែលបានប្រមូលដូចបានកត់ត្រានៅក្នុងសមតុល្យប្រចាំខែ គឺជាប្រាក់ អពទស ដែលត្រូវបង់សំរាប់ខែនោះ ។

ផ្នែកទី៦.៣:— សេវាដែលបានផ្គត់ផ្គង់

១- នៅចុងខែនីមួយៗ អ្នកផ្គត់ផ្គង់សេវាត្រូវគណនាសមតុល្យនៅក្នុងទិន្នានុប្បវត្តិ ហើយត្រូវកត់ត្រាតម្លៃសរុបនៃសេវាជាប់ អពទស ដែលបានផ្គត់ផ្គង់ និង ប្រាក់ អពទស សរុបដែលបានប្រមូលលើសេវាដែលបានផ្គត់ផ្គង់នៅក្នុងខែនោះ ។

២- ប្រាក់ អពទស សរុបដែលបានប្រមូល ដូចបានកត់ត្រានៅក្នុងសមតុល្យប្រចាំខែ គឺជាប្រាក់ អពទស ដែលត្រូវបង់សំរាប់ខែនោះ ។

ជំពូកទី៧

ការបរិច្ឆេទបង់ អពទស

ផ្នែកទី៧.១:— ការបង់ប្រាក់ អពទស

១– លើកលែងតែសកម្មភាពនាំចូល បុគ្គលជាប់ អពទស ត្រូវធ្វើការប្រកាស និងបង់ប្រាក់ អពទស ដែលត្រូវបង់សំរាប់សកម្មភាពប្រចាំខែរបស់ខ្លួនជូននាយកពន្ធដារ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់តាមទម្រង់បែបបទដែលនាយកដ្ឋានពន្ធដារបានកំណត់ ។

ជំពូកទី៨

ការតម្រូវចំពោះឃ្លាំងស្តុកទំនិញ

ផ្នែកទី៨.១:— ការចុះបញ្ជីឃ្លាំងស្តុកទំនិញ

១– អ្នកនាំចូល និងផលិតករ ទំនិញជាប់ អពទស ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារនូវឃ្លាំងជាក់លាក់សំរាប់ស្តុកទំនិញជាប់ អពទស ។ ចំនួនឃ្លាំងស្តុកទំនិញជាប់ អពទស ត្រូវមានការយល់ព្រមពីនាយកដ្ឋាន ពន្ធដារ ។

ផ្នែកទី៨.២:— ទីតាំងឃ្លាំង

១– ឃ្លាំងស្តុកទំនិញជាប់ អពទស របស់ផលិតករក្នុងស្រុកត្រូវមានទីតាំងនៅជទីកន្លែងផលិតទំនិញជាប់ អពទស ។

២– ឃ្លាំងស្តុកទំនិញជាប់ អពទស របស់អ្នកនាំចូល ត្រូវស្ថិតនៅតាមទីតាំងដែលនាយកដ្ឋានពន្ធដារ បានយល់ព្រម ។

ផ្នែកទី៨.៣:— ការតម្រូវចំពោះការស្តុកទំនិញ

១– ឃ្លាំងស្តុកទំនិញជាប់ អពទស ត្រូវបានប្រើប្រាស់សំរាប់តែស្តុកទំនិញជាប់ អពទស ប៉ុណ្ណោះ ។

២– ក្នុងករណីដែលទំនិញនាំចូលជាប់ អពទស និងទំនិញផលិតក្នុងស្រុកជាប់ អពទស ត្រូវស្តុកនៅក្នុងឃ្លាំងជាមួយគ្នា ទំនិញ២ប្រភេទនេះ ត្រូវរៀបទុកដាក់ដាច់ដោយឡែកពីគ្នា ទៅតាមបែបបទដែលនាយកដ្ឋានពន្ធដារបានយល់ព្រម ។

៣– អ្នកនាំចូល ឬ ផលិតករ ដែលជាអ្នកប្រើប្រាស់ឃ្លាំងស្តុកទំនិញជាប់ អពទស ត្រូវតែអាចបញ្ជាក់ជូននាយកដ្ឋានពន្ធដារបានថា ការបញ្ចូល បញ្ចេញ និង ស្តុកទំនិញ គឺអាចគ្រប់គ្រងបានយ៉ាងល្អ ។

ជំពូកទី៩

វិធានអន្តរកាល

ផ្នែកទី៩.១:— ការចុះបញ្ជី

១– បុគ្គលជាប់អាករ ដែលបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារបានស្រេចហើយនៅមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៧ ពុំមានកាតព្វកិច្ចត្រូវចុះបញ្ជីតាមវិធាន និងនីតិវិធីដូចមានចែងក្នុងជំពូកទី៣ទេ ។

ជំពូកទី១០

ការអនុវត្តន៍

ផ្នែកទី១០.១:— កាលបរិច្ឆេទអនុវត្ត អពទស លើយានយន្ត

១– កាលបរិច្ឆេទអនុវត្តកាតព្វកិច្ចបង់ អពទស លើយានយន្ត គឺថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៧ ដូច មានចែងក្នុងប្រកាសលេខ ០៦៧–សហវ–ប្រក–តរ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្នែកទី១០.២:— កាលបរិច្ឆេទអនុវត្ត អពទស លើសេវា

១– អាករពិសេសលើទំនិញនិងសេវាមួយចំនួន លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ត្រូវប្រមូលលើសំបុត្រយន្តហោះដែលត្រូវបានចេញ ឬ លក់អោយអ្នកដំណើរចាប់ពីថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ១៩៩៧។

២- អាករពិសេសលើទំនិញនិងសេវាមួយចំនួន លើសេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស ត្រូវប្រមូលលើសេវាដែលបានផ្ដត់ផ្គង់ ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧ ។

៣- អាករពិសេសលើទំនិញនិងសេវាមួយចំនួន ត្រូវអនុវត្តលើការជួលបន្ទប់សណ្ឋាគារទាំងអស់ ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧ តទៅ លើកលែង តែការជួលបន្ទប់ដែលមានធ្វើកិច្ចសន្យាជួលត្រឹមត្រូវនៅ មុនថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ១៩៩៧ ដែលត្រូវបានទទួលការអនុគ្រោះលើកលែងការប្រមូល អពទស រហូតដល់ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៧ ។

៤- អពទស លើសេវាលំហែកំសាន្ដ ត្រូវប្រមូលលើសេវាដែលបានផ្ដត់ផ្គង់ ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៨ ។

ផ្នែកទី១០.៣:—កាលបរិច្ឆេទអនុវត្តបទបញ្ញត្តិ និង នីតិវិធីនានា

១- កាលបរិច្ឆេទអនុវត្តបិទាននិងនីតិវិធីនានាទៀតនៃប្រកាសនេះគឺថ្ងៃទី០១ ខែកក្កដា ឆ្នាំ ១៩៩៧។

២- កាលបរិច្ឆេទអនុវត្តបទបញ្ញត្តិក្នុងកថាខ័ណ្ឌ២ នៃមាត្រា៨៥ នៃច្បាប់ស្ដីពីសារពើពន្ធដែលចែងពី មូលដ្ឋានគិត អពទស សំរាប់ផលិតផលធ្វើនៅព្រះរាជាណាចក្រកម្ពុជា គឺថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧ ។ មូលដ្ឋានគិត អពទស ចំពោះការលក់ផលិតផលធ្វើនៅព្រះរាជាណាចក្រកម្ពុជា នៅមុនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៧ គឺជាថ្លៃលក់កត់ត្រាក្នុងវិក្កយបត្ររបស់អ្នកធ្វើដែលគិតបញ្ចូលទាំងសោហ៊ុយ និង អាករគ្រប់មុខ លើកលែងតែ អពទស ខ្លួនឯងនេះ និងអាករលើផលរបរ ។

ជំពូកទី១១

អវសានបញ្ញត្តិ

ផ្នែកទី១១.១.—

- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ផ្នែកទី១១.២. — [illegible]

[illegible] ១— ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ [illegible]

[illegible]

[illegible] **រដ្ឋមន្ត្រី** [illegible]

[illegible] **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

[illegible] **ហត្ថលេខា និងត្រា**

[illegible] **គាត ឈន់**

[illegible]

[illegible]

ឧបសម្ព័ន្ធទី១

អត្រាអាករពិសេសលើទំនិញនិងសេវាមួយចំនួន (អពទស)

ភ្ជាប់ជាមួយប្រកាសលេខ : ៣៨១ ប្រក. សហវ. ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

លេខសំគាល់	រាយមុខទំនិញ	អត្រា
៨៧០៣ និង បំណែក និង គ្រឿង បន្លាស់នៃ ៨៧០៧ ៨៧០៨	រថយន្តដែលមានស៊ីឡាំងធំជាង ២.០០០ CC ព្រមទាំងគ្រឿងបន្លាស់សំរាប់ប្រភេទរថយន្តទាំងនេះ	៣០%
៨៧០៣ និង បំណែក និង គ្រឿង បន្លាស់នៃ ៨៧០៧ ៨៧០៨	រថយន្តដែលមានស៊ីឡាំងពី២.០០០ CC ចុះក្រោម ព្រមទាំងគ្រឿងបន្លាស់សំរាប់ប្រភេទរថយន្តទាំងនេះ	២០%
[illegible]	ប្រេងសាំងស៊ុបពែរ ឬធម្មតា សំរាប់យានយន្ត ប្រេងរំអិល	២០%

២២០២	ទឹកមានជាតិរ៉ែ និងទឹកមានជាតិឧស្ម័ន មានជាតិស្ករ ឬ ក៏សារជាតិផ្អែមផ្សេងទៀត ឬគ្រឿងក្រអូប និងភេសជ្ជៈដទៃទៀតដែលគ្មានជាតិស្រា លើកលែងតែទឹកផ្លែឈើ ឬ ទឹកផ្លែក្រូច និងទឹកបន្លែ ហើយនិងទឹកដមផ្លែឈើ ឬ ទឹកដម បន្លែ	១០%
២២០៣	ស្រាបៀរ	១០%
២២០៤	ស្រាទំពាំងបាយជូរស្រស់ រួមទាំងទំពាំងបាយជូរដែលមានបន្ថែមជាតិស្រា	១០%
២២០៥	ស្រាវែមុត និង ស្រាទំពាំងបាយជូរស្រស់ផ្សេងទៀត ស៊ីដ្រពែរី និងសារធាតុក្រអូប	១០%
២២០៦	ភេសជ្ជៈមេរ៉ែយផ្សេងទៀត	១០%
២២០៧	អាល់កុលអេទីលិកសុទ្ធដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះពី ៨០% នៃចំណុះ ឬ លើសពីនេះ និងអាល់កុលអេទីលិក ហើយនិងភេសជ្ជៈមានជាតិស្រាដែលកាត់បន្ថយកំរិតស្រាដើមរបស់វា ។	១០%
២២០៨	អាល់កុលអេទីលិកកាត់បន្ថយជាតិសុទ្ធដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិស្រា ភេសជ្ជៈស្រវឹងផ្សេងៗទៀតការរៀបចំកែច្នៃស្រាផ្សំក្នុងប្រភេទដែលប្រើសំរាប់ផលិតភេសជ្ជៈ ។	១០%
២៤០២	បារី បារីស៊ីហ្គាគ្រប់ប្រភេទ	១០%
៨៧០២ ៨៧០៤.២១ ដល់ ៨៧០៤.៦០ ៨៧០៦ និងបំណែក និងគ្រឿងបន្លាស់នៃ ៨៧០៧ ៨៧០៨	យានយន្តដោយរាប់បញ្ចូលទាំងរថយន្តដឹកមនុស្ស រថយន្តដឹកទំនិញ និង សាក់ស៊ីមានដាក់ម៉ាស៊ីនដែលមាន ឬ គ្មានកាប៊ីន	១០%
៨៧១១ និង បំណែក និងគ្រឿងបន្លាស់នៃ ៨៧១៤	ម៉ូតូក្រយានយន្តដែលមានស៊ីឡាំងស្ត្រាប់ពី ១២៥CC ឡើងទៅ	១០%
គ្មាន	បន្ទប់សណ្ឋាគារ	១០%

គ្មាន	ថ្លៃលក់សំបុត្រក្នុងស្រុកលើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស	២%
គ្មាន	សេវាទូរគមនាគមន៍ពីក្នុងព្រះរាជាណាចក្រកម្ពុជាទៅបរទេស	២%

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

*****

ឧបសម្ព័ន្ធទី ២

ការលើកលែង អពទស

ភ្ជាប់ជាមួយប្រកាសលេខ : ៣៤១ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១–បុគ្គលដែលគ្មានកាតព្វកិច្ចចុះបញ្ជីជាបុគ្គលជាប់អាករពិសេសលើទំនិញ និងសេវាមួយចំនួន (អពទស) អាចនាំចូលដោយរួច អពទស នូវមុខទំនិញមួយចំនួនដូចខាងក្រោម :

- បារី ២០០ ដើម
- ភេសជ្ជៈមានជាតិស្រា ២លីត្រ

- ប្រេងសាំង និង ប្រេងម៉ាស៊ូត ដែលមាននៅក្នុងធុងសាំង ឬ ម៉ាស៊ីន របស់យានយន្ត ហើយដែលមិនត្រូវលើសពីចំណុះស្តង់ដារទេ ឬកនិង
- ប្រេងសាំងស៊ុបពែរ ឬ ធម្មតា សំរាប់យានយន្ត ៣០លីត្រ
- ប្រេងម៉ាស៊ូត ៥ លីត្រ

២-ទំនិញដែលលើសពីចំនួនបានកំណត់ខាងលើ ត្រូវជាប់ អពទស ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាស លេខ ៣៤២ ប្រក.សហវ.៣៩

ស្តីពី

អាករលើផលរបរ

* * * * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្ដីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២-នស ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុម្រាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ០៨-នស-៩៤ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៤ និង ច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស-រកម ០៩៩៥-០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម ០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- បានឃើញប្រកាសលេខ ០៦៨-សហវ-តរ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ១៩៩៧ ស្ដីពីការណែនាំ អនុវត្តច្បាប់ស្ដីពីសារពើពន្ធចំពោះអាករលើផលរបរ ។

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ផ្នែកទី ១.១-មូលដ្ឋានគិតអាករលើផលរបរ

១- អាករលើផលរបរ ហៅកាត់ថា អផរប ត្រូវប្រមូលលើរាល់ការផ្គត់ផ្គង់ទំនិញ និង

សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅក្នុងមាត្រា ៣៥ និង មាត្រា៣៧ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ១៩៩៤ ។ ការនាំចេញ ឬ នាំចេញទៅវិញ នូវទំនិញ ឬ សេវា មិនត្រូវបានចាត់ទុកថាជា ការផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។ ប៉ុន្តែដើម្បីបានរួចផុតពីកាតព្វកិច្ចត្រូវប្រមូល និង បង់ អធរប ជូនរដ្ឋ បុគ្គលជាប់ អធរប ដែលផ្គត់ផ្គង់ទំនិញនាំចេញ ត្រូវបំពេញលក្ខខ័ណ្ឌដូចមានចែងក្នុងជំពូកទី ៥ នៃប្រកាសនេះ ។

២– អធរប ហៅថា អាករប្រើប្រាស់ ត្រូវប្រមូលលើការនាំចូលទំនិញមកក្នុងព្រះរាជាណាចក្រកម្ពុជា។

៣– អធរប ត្រូវប្រមូលលើរាល់ការផ្គត់ផ្គង់ទំនិញសេវា ក្រៅតែពីការផ្គត់ផ្គង់ណាដែលត្រូវបានលើកលែង ដូចមានចែងនៅក្នុងមាត្រា៣៩ និង មាត្រា៤០ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៤ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ ស្តីពីសារពើពន្ធ ។

ផ្នែក១.២– អត្រាអាករលើតម្លៃបន្ថែម

១– អាត្រា អធរប ត្រូវបានកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាសនេះ។

ផ្នែកទី ១.៣–កាលបរិច្ឆេទអនុវត្ត

១– កាលបរិច្ឆេទអនុវត្តបទប្បញ្ញត្តិនានានៃប្រកាស និង បទប្បញ្ញត្តិនានា ដូចមានចែងក្នុងកថាខ័ណ្ឌ១ ដល់កថាខ័ណ្ឌ៤ នៃមាត្រា ៨៦ នៃច្បាប់ស្តីពីសារពើពន្ធ មានចែងនៅក្នុងជំពូកទី ៩ នៃប្រកាសនេះ ។

ជំពូកទី ២

កាតព្វកិច្ចរបស់បុគ្គលជាប់អាករ

ផ្នែកទី ២.១–ការនាំចូលទំនិញ

១– អ្នកនាំចូល គឺជាបុគ្គលចុះបញ្ជីដែលបាននាំចូលទំនិញជាប់ អធរប ឬ រូបវន្ត

បុគ្គលមិនបានចុះ បញ្ជីដែលបាននាំចូលទំនិញលើសពីចំនួនត្រូវរួចពន្ធគយ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាស នេះ ។

២– អ្នកនាំចូលត្រូវបង់ អផរប លើតថាអាករប្រើប្រាស់លើទំនិញនាំចូល លើតម្លៃមានពន្ធគយ និង អាករពិសេសលើទំនិញសេវាមួយចំនួន មុនពេលយកទំនិញទាំងនោះចេញការឃុំគ្រងរបស់រដ្ឋបាលគយ។

ផ្នែកទី២.២—ការផ្គត់ផ្គង់ទំនិញ :

១– បុគ្គលជាប់ អផរប ដែលធ្វើការផ្គត់ផ្គង់ទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវប្រមូល អផរប លើការផ្គត់ផ្គង់នីមួយៗនូវទំនិញ នាពេលផ្គត់ផ្គង់ស្របតាមវិធានកំណត់តម្លៃដូចមានចែងក្នុងមាត្រា ៤១ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ១៩៩៤ ។

២– បុគ្គលជាប់ អផរប ដែលធ្វើការផ្គត់ផ្គង់ទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមកិច្ចសន្យាជួល-ទិញ ឬ កតិសន្យាហិរញ្ញវត្ថុ ត្រូវប្រមូល អផរប លើតម្លៃសរុបគ្មាន អផរប របស់ទំនិញផ្គត់ផ្គង់ដែលមានចែង នៅក្នុងកិច្ចសន្យា បូក និងបន្ទុកផ្សេងៗទាំងអស់ ដែលជាប់ទាក់ទិននិងកិច្ចសន្យានោះ ។

ផ្នែកទី២.៣—ការផ្គត់ផ្គង់សេវា :

១– បុគ្គលជាប់ អផរប ដែលធ្វើការផ្គត់ផ្គង់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រមូល អផរប លើការផ្គត់ផ្គង់នីមួយៗ នូវសេវានាពេលផ្គត់ផ្គង់ស្របតាមវិធានកំណត់តម្លៃដូចមានចែងក្នុងមាត្រា ៤២ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សម្រាប់ឆ្នាំ ១៩៩៤ ។

ផ្នែកទី២.៤—ការផ្គត់ផ្គង់ដោយខ្លួនឯង :

១– អ្នកនាំចូល ឬ អ្នកផ្គត់ផ្គង់ក្នុងស្រុក នូវទំនិញឬសេវាជាប់ អផរប ដែលបានដកយកទំនិញ ឬសេវាទាំងនោះ សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬ ការប្រើប្រាស់របស់បុគ្គលិក ឬ គតិយុជនតាមការផ្តល់ជា អំណោយ ឬ ការលក់ក្រោមតម្លៃ

ទីផ្សារ ត្រូវបង់ អផរប លើទំនិញឬសេវាតាមតម្លៃទីផ្សារ នៅពេលដកយក ទំនិញ ឬ សេវាទាំងនោះ ។

វិន្ទុកទី២.៥—ពេលផ្គត់ផ្គង់ :

១– ពេលផ្គត់ផ្គង់ ឬ ពេលដកយកទំនិញ ឬសេវា គឺជាពេលដែលបុគ្គលជាប់ អផរប ត្រូវចេញវិក្កយបត្រ ឬ ជាពេលដែលបុគ្គលនោះបានចេញវិក្កយបត្រ បើសិនជាវិក្កយបត្រត្រូវបានចេញមុនពេលដែលបុគ្គលត្រូវ ចេញវិក្កយបត្រ ។

២– ពេលដែលបុគ្គលជាប់ អផរប ត្រូវចេញវិក្កយបត្រ គឺមិនត្រូវយឺតជាង៧ថ្ងៃ :

- ក្រោយការបំពេញសេវារួច ឬ ការបញ្ចូលទំនិញ
- ក្រោយការទូទាត់ បើសិនជាការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ជូនទំនិញ ឬការបំពេញសេវា ។

៣– ការបញ្ជូនទំនិញត្រូវមានវិក្កយបត្រភ្ជាប់តាមជាកិច្ច បើសិនជាមានចេញវិក្កយបត្រហើយ លើទំនិញបញ្ជូនចេញ ។ បើសិនជានៅពេលបញ្ជូនទំនិញមិនទាន់មានចេញវិក្កយបត្រទេ ការបញ្ជូនទំនិញត្រូវមានភ្ជាប់ឯកសារបញ្ជូនទំនិញ ដែលបានកត់ត្រាត្រឹមត្រូវក្នុងទិន្នានុប្បវត្តិបញ្ជូនទំនិញរបស់បុគ្គលជាប់អផរប ។

៤– ពេលផ្គត់ផ្គង់សម្រាប់សេវាខាងហិរញ្ញវត្ថុ គឺកាលបរិច្ឆេទដែលអ្នកផ្គត់ផ្គង់សេវាត្រូវបានទទួលការប្រាក់ ប្រាក់កម្រៃ ឬកម្រៃជើងសារ ដូចមានចែងនៅក្នុងកិច្ចសន្យាផ្គត់ផ្គង់សេវាខាងហិរញ្ញវត្ថុ ឬកាលបរិច្ឆេទនៃការបង់ការប្រាក់ ប្រាក់កម្រៃ ឬ កម្រៃជើងសារ បើសិនជាការបង់ប្រាក់ត្រូវបានធ្វើឡើងមុនកាលបរិច្ឆេទដែលអ្នកផ្គត់ផ្គង់សេវា ត្រូវបានទទួលប្រាក់ ។

៥– ចំពោះទំនិញណាមួយ ដែលបានផ្គត់ផ្គង់តាមកិច្ចសន្យាជួល ទិញ ឬតាមភតិសន្យាហិរញ្ញវត្ថុ ពេលផ្គត់ផ្គង់គឺជាពេលត្រូវចេញវិក្កយបត្រ និងដែលជាពេលផ្គត់ផ្គង់ទំនិញ ។

៦– ចំពោះទំនិញដែលបានផ្គត់ផ្គង់តាមកិច្ចសន្យាជួល ឬទំនិញ ឬសេវា ដែលបានផ្គត់ផ្គង់តាមកិច្ចសន្យា ដែលមានការទូទាត់ច្រើនលើក ឬសេវាបានផ្គត់ផ្គង់ជាប់

មន្ត្រ ពេលផ្គត់ផ្គង់គឺជាពេលត្រូវចេញវិក្កយបត្រ និងដែលជាពេលត្រូវបង់ប្រាក់ ទូទាត់ណាមួយ ឬជាពេលនៃការបង់ប្រាក់ បើសិនជាមានការបង់ប្រាក់ណាមួយ ត្រូវបានធ្វើឡើងនៅមុនពេលត្រូវបង់ប្រាក់ ។

៤- ចំពោះទំនិញ ឬសេវា ដែលជាប់អាករពិសេសលើទំនិញនិងសេវាមួយចំនួន ត្រូវអនុវត្តផងដែរនូវវិធាននិងនីតិវិធី ដូចមានចែងក្នុងប្រកាសលេខ ៣៤១ ប្រក-សហវ-ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជំពូកទី ៣
ការចុះបញ្ជីបុគ្គលជាប់ អតប

ផ្នែកទី៣.១—អ្នកនាំចូលទំនិញជាប់ អតប

១- បុគ្គលដែលបាននាំចូលទំនិញសំរាប់ការលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ សំរាប់ការនាំចេញទៅវិញ ដែលជាចំណែកមួយនៃសកម្មភាពអាជីវកម្មធម្មតា របស់ខ្លួន ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារជាមុន ទើបអាចបានទទួលបុព្វសិទ្ធិ នាំចូលទំនិញមកក្នុង ឬ នាំចេញទំនិញអំពីព្រះរាជាណាចក្រកម្ពុជា ។

២- វិធានចុះបញ្ជីនេះ មិនត្រូវអនុវត្តទេ ចំពោះរូបវន្តបុគ្គលដែលនាំចូលទំនិញសំរាប់ ប្រើប្រាស់ផ្ទាល់ខ្លួន ។ រូបវន្តបុគ្គលនាំចូលទំនិញសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ដែលគ្មានកាតព្វកិច្ចចុះបញ្ជីមិនត្រូវបានលើកលែងទេ អំពីកាតព្វកិច្ចត្រូវបង់ ប្រាក់អាករលើទំនិញជាប់ អតប ។

ផ្នែក៣.២—អ្នកផ្គត់ផ្គង់ទំនិញឬសេវាជាប់ អតប

១- បុគ្គលដែលធ្វើអាជីវកម្មក្នុងការផ្គត់ផ្គង់ទំនិញឬសេវា នៅក្នុងព្រះរាជាណាចក្រ កម្ពុជា ត្រូវចុះបញ្ជីនៅនាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុត ១៥ថ្ងៃ ក្រោយពេល ចាប់ផ្ដើមការផ្គត់ផ្គង់ទំនិញ ឬ សេវា ។

២- បទប្បញ្ញត្តិអន្តរកាលសំរាប់អ្នកផ្គត់ផ្គង់បច្ចុប្បន្ននូវទំនិញឬសេវាជាប់ អតប មាន ចែងក្នុងជំពូកទី ៩ នៃប្រកាសនេះ ។

ជំពូកទី ៤

ការតម្រូវនានាចំពោះការកត់ត្រាគណនេយ្យ

ផ្នែកទី៤.១—ការតម្រូវចំពោះទំនិញនាំចូលជាប់ អតប

១- ចំពោះការនាំចូលទំនិញមកក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាសំរាប់ការប្រើប្រាស់ក្នុងស្រុក ឬ សំរាប់ការនាំចេញទៅវិញ និង ទោះបីជាទំនិញទាំងនោះ ត្រូវបានដឹកមកពីប្រទេសណាក៏ដោយ អ្នកនាំចូលត្រូវកាន់កាប់បញ្ជីនាំចូលប្រចាំថ្ងៃ និងត្រូវកត់ត្រានូវពត៌មានដូចខាងក្រោម ទាក់ទិននឹងការនាំចូលនីមួយៗ ។

- លេខ និង កាលបរិច្ឆេទ ប្រតិវេទន៍គយសំរាប់ការនាំចូល ឈ្មោះអង្គភាពគយដែលបានពិនិត្យអនុញ្ញាត អោយទំនិញចូល និង កាលបរិច្ឆេទយកទំនិញចេញអំពីការឃុំគ្រងរបស់រដ្ឋបាលគយ ដើម្បីនាំចូលមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បរិមាណ គុណភាព ទម្ងន់ លេខសេរី បើសិនជាមាន និងបរិយាយមុខទំនិញនាំចូលតាមលេខសំគាល់គយនិងតាមម៉ាក
- តម្លៃឯកតា និង តម្លៃសរុបរបស់ទំនិញនាំចូល ពត៌មានសង្ខេបអំពីតម្លៃសរុបនៃទំនិញនាំចូលក្នុងនោះ មានថ្លៃដើមទំនិញ និងសង្ខេបអំពីតម្លៃផ្សេងៗទៀតដែលជាចំណែកនៃតម្លៃសរុបរបស់ទំនិញនាំចូល
- ចំនួនប្រាក់ពន្ធគយ ដែលបានបង់
- ចំនួនប្រាក់អាករពិសេសលើទំនិញនិងសេវាមួយចំនួន ដែលបានបង់បើសិនជាមាន
- ចំនួនប្រាក់ អតប ហៅថាអាករប្រើប្រាស់ដែលបានបង់
- កាលបរិច្ឆេទ និង លេខបង្កាន់ដៃបង់ពន្ធ
- កាលបរិច្ឆេទទំនិញនាំចូល ត្រូវបានដឹកចូលឃ្លាំងអ្នកនាំចូល និង

- បរិមាណតាមលេខសំគាល់គយ និង តាមម៉ាកនៃទំនិញដែលបាននាំចូលសំរាប់នាំចេញទៅវិញ ។

២- អ្នកនាំចូលទំនិញត្រូវកាន់កាប់ទិន្នានុប្បវត្តិលក់ប្រចាំថ្ងៃ និងត្រូវកត់ត្រានៅពេលផ្គត់ផ្គង់នូវពត៌មានដូចខាងក្រោម សំរាប់ការផ្គត់ផ្គង់ទំនិញនិមួយៗ :

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខរៀងវិក្កយបត្រ
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទិញ ហើយនិងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើសិនជាមាន
- សេចក្តីបរិយាយអំពីទំនិញលក់ចេញតាមលេខសំគាល់គយ និងតាមម៉ាក
- តំលៃឯកតា និង តំលៃសរុបរបស់ទំនិញលក់ចេញមានអាករពិសេសលើទំនិញនិងសេវាមួយចំនួននិង គ្មាន អផរប
- ចំនួនប្រាក់ អផរប ត្រូវប្រមូល និង
- កាលបរិច្ឆេទបញ្ជូនទំនិញ បើសិនខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ ។

៣- បញ្ជីនាំចូល និង ទិន្នានុប្បវត្តិលក់ ត្រូវធ្វើតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវមានចុះលេខទំព័រ និងចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិ ប្រទាន ។

ផ្នែកទី៤.២–ការតម្រូវចំពោះការផ្គត់ផ្គង់ទំនិញឬសេវាជាប់ អផរប

១- បុគ្គលជាប់ អផរប ត្រូវកាន់កាប់ទិន្នានុប្បវត្តិទិញប្រចាំថ្ងៃ និង ត្រូវកត់ត្រាពត៌មាន ដូចខាងក្រោម លើការទិញនិមួយៗ :

- កាលបរិច្ឆេទវិក្កយបត្រ
- លេខរៀងវិក្កយបត្រ
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកផ្គត់ផ្គង់ ហើយនិងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកផ្គត់ផ្គង់ បើសិនជាអ្នកផ្គត់ផ្គង់នោះ ជាអ្នកជាប់ពន្ធតាមរបបពិត

- សេចក្ដីបរិយាយអំពីសេវាផ្គត់ផ្គង់ ឬ ទំនិញទិញចូល តាមម៉ាក និង តាមប្រភេទ
- តម្លៃរបស់សេវាផ្គត់ផ្គង់ ឬ តម្លៃឯកតា និង តម្លៃសរុបរបស់ទំនិញទិញចូល ដែលមានរួមបញ្ចូលនូវ បន្ទុកនានាជាប់ទាក់ទិននឹងការផ្គត់ផ្គង់នោះ និងដែលគ្មាន អធរប
- តម្លៃមាន អធរប របស់សេវាផ្គត់ផ្គង់ ឬ ទំនិញទិញចូល និង
- កាលបរិច្ឆេទនៃការផ្គត់ផ្គង់សេវា ឬ កាលទទួលទំនិញ បើសិនជាខុសគ្នាពីកាលបរិច្ឆេទវិក្កយបត្រ ។

២- បុគ្គលជាប់ អធរប ត្រូវកាន់កាប់ទិន្នានុប្បវត្តិលក់ប្រចាំថ្ងៃ និង ត្រូវកត់ត្រានៅពេលផ្គត់ផ្គង់នូវពត៌មានដូចខាងក្រោម លើការផ្គត់ផ្គង់និមួយៗដែលបុគ្គលនោះបានធ្វើ :

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខរៀងវិក្កយបត្រ
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទិញ ហើយនិងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើសិនជាមាន
- សេចក្ដីបរិយាយអំពីសេវាផ្គត់ផ្គង់ ឬ ទំនិញលក់ចេញ តាមម៉ាក និង តាមប្រភេទ
- តម្លៃរបស់សេវាផ្គត់ផ្គង់ ឬ តម្លៃឯកតា តម្លៃសរុបរបស់ទំនិញលក់ចេញ ដែលមានរួមបញ្ចូលនូវបន្ទុក ជាប់ទាក់ទិននឹងការផ្គត់ផ្គង់នោះ និងដែលគ្មាន អធរប
- តម្លៃ អធរប របស់សេវាផ្គត់ផ្គង់ ឬ ទំនិញលក់ចេញ និង
- កាលបរិច្ឆេទនៃការផ្គត់ផ្គង់សេវា ឬការបញ្ជូនទំនិញ បើសិនជាខុសគ្នាពីកាលបរិច្ឆេទចេញវិក្កយបត្រ

៣- ទិន្នានុប្បវត្តិទិញ និងទិន្នានុប្បវត្តិលក់ ត្រូវធ្វើតាមទម្រង់ដែលនាយកដ្ឋានពន្ធដារបានកំណត់ និងត្រូវ មានចុះលេខទំព័រ និង ចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងដែលមានសិទ្ធិ ប្រទាន ។

៤- បុគ្គលជាប់ អផរប ដែលធនាគារជាតិនៃកម្ពុជា បានកំណត់ថាជាធនាគារ ត្រូវកាន់កាប់បញ្ជី និង កំណត់ត្រាប្រចាំថ្ងៃ តាមការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

ផ្នែកទី៤.៣:—វិក្កយបត្រ

១- បុគ្គលជាប់ អផរប ដែលធ្វើការផ្គត់ផ្គង់ទំនិញឬសេវា សម្រាប់លក់ក្នុងស្រុក ឬសម្រាប់ការនាំចេញ ត្រូវចេញវិក្កយបត្រមានលេខរៀង ដែលមានចុះពត៌មានដូចខាងក្រោម សម្រាប់ការផ្គត់ផ្គង់និមួយៗ:

- កាលបរិច្ឆេទចេញវិក្កយបត្រ
- លេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកលក់
- ឈ្មោះ និង អាសយដ្ឋានរបស់អ្នកទិញ ហើយនិងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកទិញ បើសិនជាមាន
- ប្រភេទសេវាដែលបានផ្គត់ផ្គង់ ឬបរិមាណ និង សេចក្តីបរិយាយអំពីទំនិញដែលបានលក់តាមម៉ាក និង តាមប្រភេទ
- តម្លៃសេវាដែលបានផ្គត់ផ្គង់ ឬតម្លៃឯកតា និងតម្លៃសរុបរបស់ទំនិញដែលបានលក់គ្មាន អផរប
- ប្រាក់ អផរប ត្រូវប្រមូល
- តម្លៃមាន អផរប របស់ទំនិញ ឬសេវា ដែលបានផ្គត់ផ្គង់ និង
- ក្នុងករណីដែលទំនិញមានរាយលំអិតត្រូវបានលក់សំរាប់ការនាំចេញ ត្រូវមានចុះបញ្ជាក់ថា«ទំនិញរាយលំអិតទាំងនេះ សំរាប់នាំចេញពីព្រះរាជាណាចក្រកម្ពុជា»។

២- បណ្តាធនាគារត្រូវកាន់កាប់បញ្ជី និងកំណត់ត្រា លើការផ្តល់ប្រាក់អោយខ្ចី និង ការទទួលសំណងជាប្រាក់ដើម និងការប្រាក់ ស្របតាមវិធាននិងនីតិវិធីកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

៣– បុគ្គលជាប់ អធរប ត្រូវរក្សាទុកវិក្កយបត្រដែលបានចេញ [illegible] ទាំងអស់ និង វិក្កយបត្រ [illegible] តាមលំដាប់ថ្ងៃខែ និងនៅតាមទីកន្លែងដែលនាយកដ្ឋានពន្ធដារបានយល់ព្រម ។

៤– បើសិនជាត្រូវធ្វើការកែតម្រូវចំពោះវិក្កយបត្រណាមួយ ត្រូវភ្ជាប់ជាមួយនិងវិក្កយបត្រនេះនូវច្បាប់ចម្លង ឯកសារគណនេយ្យដែលកត់ត្រាការកែតម្រូវ ។

ផ្នែកទី៤.៤—ការតម្រូវចំពោះការទុកដាក់ឯកសារ

១– បុគ្គលជាប់អាករត្រូវកាន់កាប់ និងរក្សាទុកនូវបញ្ជីទិន្នានុប្បវត្តិ និងវិក្កយបត្រទាំងអស់នៅតាមទីកន្លែងដែលនាយកដ្ឋានពន្ធដារបានយល់ព្រម ក្នុងរយៈពេល ១០ឆ្នាំ ក្រោយកាលបរិច្ឆេទចេញវិក្កយបត្រ ឬ ក្រោយកាលបរិច្ឆេទនៃការកត់ត្រាចុងក្រោយបំផុត នៅលើបញ្ជី ឬ ទិន្នានុប្បវត្តិ ។

ជំពូកទី ៥

ការផ្តត់ផ្គង់សំរាប់នាំចេញ

ផ្នែកទី៥.១—ការនាំចេញទំនិញ និងសេវា

១– ទំនិញនាំចូល សម្រាប់លក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបង់ អធរប ។

២– ទំនិញនាំចូល សម្រាប់នាំចេញត្រូវរួចផុតពីការបង់ អធរប ។ ចំពោះល័ក្ខខណ្ឌ និងនីតិវិធីនៃការអនុវត្តន៍រួចផុតពី អធរប ត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣– បុគ្គលជាប់ អធរប ដែលនាំចេញសេវាត្រូវផ្តល់ជូននាយកដ្ឋានពន្ធដារនូវឯកសារនានាដូចខាងក្រោម ដើម្បីបានរួចផុតពីកាតព្វកិច្ចត្រូវប្រមូល អធរប លើសេវាទាំងនោះ :

– វិក្កយបត្រសំរាប់សេវានាំចេញ ដែលបុគ្គលជាប់ អធរប បានចេញ

– ភស្តុតាងបញ្ជាក់ពីការទូទាត់ថ្លៃសេវានាំចេញ ដែលត្រូវធ្វើតាមវិធីផ្ទេរប្រាក់ធនាគារ ។

ផ្នែកទី៥.២–សេវាដឹកជញ្ជូន

១– ចំពោះសេវាដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវគោក និងផ្លូវទឹក បុគ្គលជាប់ អផរប ត្រូវប្រមូល អផរប លើចំណែកនៃការដឹកជញ្ជូនដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២– ចំពោះសេវាដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស បុគ្គលជាប់ អផរប ត្រូវប្រមូល អផរប លើការហោះហើរក្នុងចំណែកណាដែលមានចំណុចចេញដំណើរ និងចំណុចទៅដល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលគ្មានការចុះសំចតក្នុងចន្លោះចំណុចទាំងពីរនេះ ។

ជំពូកទី ៦

ការគណនាប្រាក់អាករត្រូវបង់

ផ្នែកទី៦.១–ការនាំចូលទំនិញ

១– ប្រាក់ អផរប លើទំនិញនាំចូលត្រូវគណនាតាមវិធាន និងនីតិវិធី ដូចមានចែងក្នុងប្រកាសលេខ ០៦៥-សហវ-ប្រក-គរ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ផ្នែកទី៦.២–ការផ្គត់ផ្គង់ទំនិញ

១– នៅចុងខែនិមួយ បុគ្គលជាប់អាករត្រូវតែគណនាសមតុល្យនៅក្នុងទិន្នានុប្បវត្តិលក់ ហើយត្រូវកត់ត្រា តម្លៃសរុបនៃការផ្គត់ផ្គង់ទំនិញជាប់ អផរប និងប្រាក់ អផរប សរុបដែលបានប្រមូលនៅក្នុងខែនោះលើទំនិញផ្គត់ផ្គង់ ។

២– ប្រាក់ អផរប សរុបដែលបានប្រមូល ដូចបានកត់ត្រានៅក្នុងសមតុល្យប្រចាំខែណាមួយគឺជាប្រាក់ អផរប ដែលត្រូវបង់សំរាប់ខែនោះ ។

៣– អ្នកនាំចូលដែលធ្វើការផ្គត់ផ្គង់ទំនិញ ដែលខ្លួនបាននាំចូលដោយផ្ទាល់សម្រាប់លក់ក្នុងប្រទេស និងសម្រាប់នាំចេញ ត្រូវគណនាប្រាក់ អផរប ត្រូវបង់តាមវិធាន និងនីតិវិធីដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្នែកទី៦.៣—ការផ្គត់ផ្គង់សេវា

១– [illegible] ខែនិមួយៗ បុគ្គលជាប់អាករត្រូវគណនាសមតុល្យនៅក្នុងទិន្នានុប្បវត្តិលក់ ហើយត្រូវកត់ត្រាតម្លៃសរុបនៃការផ្គត់ផ្គង់សេវាជាប់ អធរប និងប្រាក់ អធរប សរុប ដែលបានប្រមូលនៅក្នុងខែនោះលើសេវាផ្គត់ផ្គង់ ។

២– ប្រាក់ អធរប សរុបដែលបានប្រមូល ដូចបានកត់ត្រានៅក្នុងសមតុល្យប្រចាំខែណាមួយគឺជាប្រាក់ អធរប ដែលត្រូវបង់សំរាប់ខែនោះ ។

ជំពូកទី ៧

ភារកិច្ចរបស់បុគ្គលជាប់ អធរប

ផ្នែកទី៧— ការបង់ប្រាក់ អធរប លើការផ្គត់ផ្គង់ទំនិញ និងសេវា

១– បុគ្គលជាប់ អធរប ត្រូវធ្វើការប្រមូល និងបង់ប្រាក់ ដែលត្រូវបង់សំរាប់សកម្មភាពប្រចាំខែរបស់ខ្លួន ជូននាយកដ្ឋានពន្ធដារ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ តាមទម្រង់បែបបទដែលនាយកដ្ឋានពន្ធដារបាន កំណត់ ។

ជំពូកទី ៨

វិធានអន្តរកាល

ផ្នែកទី ៨. ការចុះបញ្ជី

១– បុគ្គលជាប់ អធរប ដែលបានចុះបញ្ជីនៅនាយកដ្ឋានពន្ធដារបានស្រេចហើយ នៅមុនថ្ងៃទី០១ ខែមិថុនា ឆ្នាំ ១៩៩៧ ពុំមានភារកិច្ចត្រូវចុះបញ្ជីតាមវិធាន និងនីតិវិធី ដូចមានចែងក្នុងជំពូកទី៣ទេ ។

ជំពូកទី ៩

ការអនុវត្តន៍

ផ្នែកទី៩.១—ការលើកលែងអនុវត្ត អធរប

១– ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៧ ការលក់ដូរទំនិញនាំចូល ដែលអ្នកនាំចូល

លក់ទំនិញនោះផ្ទាល់ខ្លួននៅក្នុងប្រទេស ត្រូវជាប់ អផរប ដូចមានចែងក្នុង សេចក្តីជូនដំណឹងលេខ ០០៦ សជណ-សហវ-ពដ ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២– ប្រាក់ អផរប លើការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ មិនត្រូវ ប្រមូលទៅលើសំបុត្រ យន្តហោះដែលបានចេញ ឬលក់អោយអ្នកដំណើរ ចាប់ពី ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ១៩៩៧ ។

៣– កាលបរិច្ឆេទអនុវត្តវិធាន និង នីតិវិធីនានាទៀតនៃប្រកាសនេះ គឺថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧ ។

ជំពូកទី ១០

អវសានប្បញ្ញត្តិ

ផ្នែកទី១០.១–

១– បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ផ្នែកទី១០. [redacted]

១– ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

* * *

ឧបសម្ព័ន្ធទី ១
អត្រាអាករលើផលរបរ

ភ្ជាប់ជាមួយប្រកាសលេខៈ ៣៨២ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧
របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផលរបរជាប់ រផរប	អត្រា
ផលរបរសម្រេចបានពីសកម្មភាពឧស្សាហកម្ម សិប្បកម្ម និង អណ្តូងរ៉ែ	១%
– ផលរបរបានមកពីប្រតិបត្តិការជួលធ្វើឡើងក្នុងសណ្ឋាគារ និងសេវាជាឧបសម្ព័ន្ធទាំងឡាយដែលទាក់ទងផ្ទាល់ទៅនឹងសណ្ឋាគារ – ផលរបរបានមកពីការជួលបន្ទប់សំនៅ បំពាក់ដោយចលនវត្ថុធ្វើឡើងដែលមានលក្ខណៈជាវិជ្ជាជីវៈ – ផលរបរសម្រេចបាននៅក្នុងគ្រឹះស្ថាន ម៉ាស្សា រង្គសាល និង ទីលំហែកំសាន្តនានា – ផលរបរសម្រេចបាននៅក្នុងភោជនីយដ្ឋាន និង ភេសជ្ជដ្ឋាន	១០%
ផលរបរសម្រេចបានដោយអាជីវកម្មផ្សេងទៀត	៥%

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

* * * * *

ឧបសម្ព័ន្ធទី ២

ការលើកលែង អផរប

ភ្ជាប់ជាមួយប្រកាសលេខៈ ៣៨២ ប្រក.សហវ.ពដ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧
របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១-បុគ្គលដែលគ្មានកាតព្វកិច្ចចុះបញ្ជីជាបុគ្គលជាប់អាករលើផលរបរ (អផរប) អាចនាំចូលដោយរួម អផរប ហៅថាអាករប្រើប្រាស់ នូវមុខទំនិញមួយចំនួនដូចខាងក្រោម នៅពេលដែលបុគ្គលនោះឆ្លងដែនដោយស្របច្បាប់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា :

- បារី ២០០ ដើម
- ភេសជ្ជៈមានជាតិសុរា ២ លីត្រ
- ប្រេងសាំង និង ប្រេងម៉ាស៊ូត ដែលមាននៅក្នុងធុងសាំង ឬ ម៉ាស៊ីនរបស់យានយន្ត ហើយដែលមិនត្រូវលើសពីចំណុះស្តង់ដារទេ បូកនឹង
- ប្រេងសាំងស៊ុបពែរ ឬ ធម្មតា សំរាប់យានយន្ត ៣០ លីត្រ
- ប្រេងម៉ាស៊ូត ៥ លីត្រ

២-ទំនិញដែលលើសពីចំនួនបានកំណត់ខាងលើ ត្រូវជាប់ អផរប ហៅថាអាករប្រើប្រាស់។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
គាត ឈន់

* * * * *

២- និតិការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៥០ ពណ.ករបប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមកិច្ចព្រមព្រៀងស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង ការការពារកម្មសិទ្ធិបញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ ខែ តុលា ១៩៩៦
- យោងតាមការចាំបាច់នៃការងារ

សំរេច

ត្រូវបានបំពេញបន្ថែមក្នុងប្រកាសលេខ៣៥០ ពណ.ពកប ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ត្រង់ប្រការ៤ ចំណុច១ គឺបន្ថែម«គំរូពាក្យសុំលេខ GSPOO2 ដូចមានភ្ជាប់ » ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ហត្ថលេខា និងត្រា
ចម ប្រសិទ្ធ

* * * * *

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ....

លេខ.......................................**ទីថ្ងៃ**.......................................

ឧរសព្ទ.......................................**ទូរសារ**.......................................

គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កម្មវត្ថុ : ពាក្យសុំចុះឈ្មោះក្នុង «បញ្ជីឈ្មោះក្រុមហ៊ុនដែលមានសិទ្ធិទទួលអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះទូទៅ និង ពីលក្ខណៈសម្បត្តិជាប្រជាជាតិមានភាពអនុគ្រោះជាងគេ» (បញ្ជី GSP/MFN)

ខ្ញុំបាទមានកិត្តិយសសូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យលទ្ធភាពចុះឈ្មោះក្រុមហ៊ុនខ្ញុំបាទនៅក្នុងបញ្ជី(GSP/MFN)ដែលកាន់កាប់ដោយការិយាល័យប្រព័ន្ធអនុគ្រោះទូទៅចំណុះក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនខ្ញុំបាទមានចុះបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី..............លេខ.................

ក្រុមហ៊ុនខ្ញុំបាទដំណើរការនាំចេញ.........................ចាប់ពីថ្ងៃទី.......................

ហើយមានបំណងនាំចេញទៅលក់នៅបរទេសដោយទទួលអត្ថប្រយោជន៍ពីប្រព័ន្ធអនុគ្រោះទូទៅ និង ពីលក្ខណៈសម្បត្តិជាប្រជាជាតិមានភាពអនុគ្រោះជាងគេ ដែលព្រះរាជាណាចក្រកម្ពុជាកំពុងទទួលពីបណ្ដាប្រទេសអភិវឌ្ឍន៍លើសកលលោក ។

ខ្ញុំបាទសូមសន្យាថា ក្រុមហ៊ុនយើងខ្ញុំនឹងមិនធ្វើសកម្មភាពណាមួយ ដែលរំលោភលើបែបបទប្រភពដើមខាងលើ នាំអន្តរាយដល់កិត្តិនាម អាយុជីវិត នៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាឡើយ ។

ខ្ញុំសូមសន្យាថាក្រុមហ៊ុនខ្ញុំនឹងមិនប្រព្រឹត្តិល្មើសដូចខាងក្រោមនេះ :

១– ការផ្ទេរទំនិញដោយខុសច្បាប់ ឬ ការលួចបន្លំផ្លូវដឹកទំនិញក្នុងគោលបំណងគេចវេសពីវិធានប្រភពទំនិញអនុវត្ត ដោយប្រទេសអភិវឌ្ឍន៍ ដែលនាំចូលទំនិញ ។

២– ការ[illegible]សក្លែងបន្លំអំពីប្រទេសជាប្រភពដើមនៃទំនិញ ។

៣– ការក្លែងបន្លំឯកសារផ្លូវការរបស់រដ្ឋ

៤– ទំនិញដែលនាំចេញត្រូវធានាថាទំនិញទាំងនោះសុទ្ធតែផលិតនៅប្រទេសកម្ពុជា ។

៥– លួចបន្លំនាំចេញទំនិញដែលផលិតផលបន្តិចបន្តួចនៅក្នុងប្រទេសកម្ពុជាជាមួយបរិមាណទំនិញសន្ធឹកសន្ធាប់ផលិតនៅប្រទេសក្រៅ ។

៦– លួចបន្លំបញ្ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជានូវផលិតផលដែលផលិតនៅក្រៅប្រទេស និងក្លែងបន្លំវិញ្ញាបនបត្រផ្ទុកទំនិញ ដើម្បីមកស៊ុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើម។

៧– លួចបន្លំផ្ទុកទំនិញដែលរដ្ឋ និង អន្តរជាតិហាមឃាត់។

៨– ប្រើប្រាស់ឯកសារក្លែងក្លាយមកស៊ុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ។

៩– ប្រព្រឹត្តល្មើសណាមួយ ដែលប៉ះពាល់ដល់កិត្តិនាមនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីក្រុមហ៊ុនខ្ញុំមិនគោរពតាមពាក្យសន្យានេះ ខ្ញុំសូមឯកភាពអោយក្រសួងពាណិជ្ជកម្មដាក់ទណ្ឌកម្មដល់ក្រុមហ៊ុនខ្ញុំបាទដោយផ្អាក ឬ បញ្ឈប់ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ហើយមិនទទួលស្គាល់លើរាល់ឯកសារសំរាប់ការនាំចេញផលិតផលនៃក្រុមហ៊ុនខ្ញុំ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ....

នាយកក្រុមហ៊ុន..

(ហត្ថលេខានិងត្រា)

ឈ្មោះ

ឈ្មោះក្រុមហ៊ុន :

ទីស្នាក់ការ :

ទូរស័ព្ទលេខ : ទូរសារលេខ :

ឈ្មោះធនាគារដែលបើកគណនី :

វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម : លេខ :

១- ដើមទុនក្រុមហ៊ុន :

២- ប្រភេទក្រុមហ៊ុន :

៣- សកម្មភាពអាជីវកម្ម : នាំចេញ

កាលបរិច្ឆេទនៃការចាប់ផ្តើមនាំទំនិញចេញ

ល.រ	ម្ចាស់ដើមទុន	អាស័យដ្ឋាន	សញ្ជាតិ	%នៃហ៊ុន	ដើមទុន	មុខរបរ

ទុនត្រូវបានបែងចែក................ភាគហ៊ុន ។ ក្នុងមួយភាគរយស្មើ..................

ប្រភេទវិញ្ញាបនប[illegible]ដែលត្រូវការ :

- ☐ វិញ្ញាបនបត្រប្រភពដើមធម្មតា
- ☐ វិញ្ញាបនបត្រប្រភពដើមទំរង់ A(GSP From A)

គំរូហត្ថលេខាសំរាប់ពាក្យស្នើសុំវិញ្ញាបនបត្រប្រភពទំនិញទំរង់ A និងវិញ្ញាបនបត្រប្រភពដើមធម្មតា

ឈ្មោះអ្នកស្នើសុំ មុខងារ	គំរូហត្ថលេខា
ឈ្មោះអ្នកស្នើសុំ មុខងារ	គំរូហត្ថលេខា
ឈ្មោះអ្នកតំណាង មុខងារ	គំរូហត្ថលេខា

ក្រសួងពាណិជ្ជកម្ម ការិយាល័យ GSP

សេចក្តីប្រកាស និង ការអនុវត្តន៍

១–ខ្ញុំ/យើងដែលបានចុះហត្ថលេខាដូចខាងក្រោមនេះ សូមប្រកាសថា ព[illegible]ល ផ្តល់អោយក្នុងពាក្យសុំនេះ ពិតជាត្រឹមត្រូវ និង ពិតប្រាកដមែន ។

២– តាមល័ក្ខខ័ណ្ឌជាមុនសំរាប់ចុះបញ្ជីសិទ្ធិបញ្ជាបនបត្រដើមនៃទំនិញ ។

៣–ខ្ញុំ/យើងនឹងធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយមន្ត្រីទទួលបន្ទុក GSP ប្រសិនបើខ្ញុំ/យើងត្រូវបានមន្ត្រីទាំងនោះតម្រូវអោយមានធ្វើការត្រួតពិនិត្យ ។

៤–ខ្ញុំ/យើងនឹងធ្វើការផ្តល់ពត៌មានភ្លាមដល់ក្រុមអភិបាលត្រួតពិនិត្យនាំចេញនាំចូល និង មជ្ឈមណ្ឌលជាតិប្រព័ន្ធអនុគ្រោះទូទៅ ក្នុងករណីមានការផ្លាស់ប្តូរអ្វីមួយប្លែកពីធម្មតាក្នុងពាក្យសុំនេះ ។

៥–ខ្ញុំ/យើងព្រមទទួលកំហុសក្នុងករណីដែលធ្វើសេចក្តីប្រកាសមិនត្រឹមត្រូវ ឬ ក្លែងក្លាយដោយគោរពទៅតាមច្បាប់ជាធរមាន ។

ហត្ថលេខា

ឈ្មោះ :

មុខងារ :

កាលបរិច្ឆេទ : ត្រាក្រុមហ៊ុន

ពាណិជ្ជកម្ម ការិយាល័យ GSP

ផែនទីគំនូសបំព្រួញទីតាំងក្រុមហ៊ុន :

ក្រសួងពាណិជ្ជកម្ម ការិយាល័យ GSP

៣- និស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៤៧៧ ស្នន ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គៀង អៀងគាន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២០២៤៧៦ ភ.ព ចុះថ្ងៃទី ១៦_៦_៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២០៧ ABCE0 ផ្លូវទេពផន សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតកាហ្វេ និងតែនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **គៀង អៀងគាន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលកាហ្វេសញ្ញា «រូបម្កុដ» និងតែសញ្ញា «រូបក្ងោក១» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៧៨ ស្នន.ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ស្រេង អៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣៩៤៩៤ ភ.ព ចុះថ្ងៃទី ០២_៦_៨៩ អាស័យដ្ឋាន

បច្ចុប្បន្ន ផ្ទះលេខ ៧៦ A ផ្លូវលេខ ១០៣ សង្កាត់បឹងកេងកងទី៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតតែកញ្ចប់នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ស្រេង សឿន** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលតែកញ្ចប់សញ្ញា «រូប ក្តាន់មាស១» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ៤៧៩ ស្តន ឧក. ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ស្រេង ទី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣៩៤០៤ ភ.ព ចុះថ្ងៃទី ០៣_៦_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧១១ E0 វិថីមុនីវង្ស ក្រុមទី១៦ សង្កាត់បឹងកេងកងទី៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតតែកញ្ចប់នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ស្រេង ទី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលតែកញ្ចប់សញ្ញា «រូបស្វា ១២» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨០ សហវ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែវុសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ចៅ ចាន់** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៦៥៤ ប.ប ចុះថ្ងៃទី ១៣_១១_៩៣ អាស័យដ្ឋានបច្ចុប្បន្នភូមិកំពង់ក្របី ឃុំស្វាយចៅ ស្រុកស្វាយចៅ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីន កិនស្រូវកំលាំង ៦០សេះ នៅក្នុងទីតាំងភូមិសាលាបាឡាត់ ឃុំអូរម៉ាល់ ស្រុកស្វាយ ចៅ ខេត្តបាត់ដំបង ។

ប្រការ ២ : អ្នកស្រី **ចៅ ចាន់** ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨១ ស្តន ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **យុត ដៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៦២២១ ប.ប ចុះថ្ងៃទី ០៦_១២_៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិ បឹងរាំង ឃុំអូរម៉ាល់ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៥០សេះ នៅក្នុងទីតាំងភូមិបឹងរាំង ឃុំអូរម៉ាល់ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង។

ប្រការ ២ : លោក **យុត ដៀង** ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្ចង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨២ ស្តន ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **តាំង ហួត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០១០១០ ប.ប ចុះថ្ងៃទី ៣០_៨_៨៥ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិ អូរចារ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ៥៧សេះ នៅក្នុងទីតាំងភូមិអូរចារ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **តាំង ហួត** ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨៣ ផក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឌុច គីមឈៀន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៩១២១ ប.ជ ចុះថ្ងៃទី ៣០_៨_៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិ ប្ញូរ ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១០៩សេះ នៅក្នុងទីតាំងភូមិប្ញូរ ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

ប្រការ ២ : អ្នកស្រី **ឌុច គីមឈៀន** ត្រូវបន្តដំណើរការផលិតកម្ម_អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨៤ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **គីម យ៉ិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨៣៨៥២ ប.ប ចុះថ្ងៃទី ១៤_៥_៩២ អាស័យដ្ឋាន បច្ចុប្បន្នភូមិអញ្ចាញ ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការ រោងជាងផ្សារដែក នៅក្នុងទីតាំងភូមិ ព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការ ប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

*****

ប្រកាសលេខ ៤៨៥ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈឿន នុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០០២៦១៣ ប.ប ចុះថ្ងៃទី ១៤_៩_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកាប់គោថ្មី ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងជាងក្រឡឹងផ្សារដែកនៅក្នុងទីតាំងភូមិ កាប់គោថ្មី ឃុំអូរចារ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៨៦ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឡយ ឆិច** សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១៦៥៦ប.ប ចុះ ១៣-១១-៩៣ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ១៣ មករា ឃុំព្រែកព្រះស្តេច ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៦០ សេះ នៅក្នុងទីតាំងភូមិអណ្តូងព្រីង ឃុំអូរម៉ាល់ ស្រុកស្វាយប៉ោ ខេត្ត បាត់ដំបង ។

ប្រការ ២ : លោក **ឡយ ឆិច** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨៧ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឌី គុចខួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០១១០២៦ ប.ប ចុះថ្ងៃទី ១០_០១_៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិឡឥដ្ឋ ឃុំព្រែកព្រះស្តេច ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំងភូមិ ព្រាបក្រសាំង ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឌី នុខខ្លួន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៨៨ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឈឿង ឈ្លាង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៩៣៥៤ប.ប ចុះថ្ងៃទី ២៥–៣–៨៨ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិចុងប្រឡាយ ឃុំតាលាស ស្រុកមោងឫស្សី ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៩០ សេះ នៅក្នុងទីតាំងភូមិព្រៃព្រាល ឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឈឿង ឈ្លាង** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៨៩ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី អ៊ុក ស ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៨៤៨១ ប.ប ចុះថ្ងៃទី ០៦_១២_៨៥ អាស័យដ្ឋានបច្ចុប្បន្នភូមិទួលតាឯក ឃុំទួលតាឯក ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងភូមិកញ្ជ្រោង ឃុំចាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : អ្នកស្រី អ៊ុក ស ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៩០ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានអ្នកស្រី ឡូន ទ៉ិច ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៥៣៩៤ប.ប ចុះថ្ងៃទី ២៧_១០_៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្មដោយប្រើម៉ាស៊ីនកំលាំង ១២០សេះ នៅក្នុងទីតាំងភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : អ្នកស្រី **នួន ម៉ិច** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៩១ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ម៉ុខ ឈៀង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៣៣៧៨ ប.ប ចុះថ្ងៃទី ០៩–១០–៨៦ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិ ប្រាបក្រសាំង ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៦០ សេះ នៅក្នុងទីតាំងភូមិប្រាបក្រសាំង ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ម៉ុខ ឈៀង** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ៤៩២ ជក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ក់ សុផាត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៤៣២៤ ប.ប ចុះថ្ងៃទី ០៥_៧_៩១ អាស័យដ្ឋានបច្ចុប្បន្នភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ម៉ក់ សុផាត** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៩៣ ជក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឈាន ហ៊ិញ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៦១០៥ ប.ប ចុះថ្ងៃទី ១៤_១០_៨៧ អាស័យដ្ឋានបច្ចុប្បន្នភូមិកំពង់ឆ្នង ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០ សេះ នៅក្នុងទីតាំងភូមិកំពង់ឆ្នង ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : អ្នកស្រី **ឈាន ហ៊ិញ** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៩៤ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឡេង សេង** ជនជាតិខ្មែរសញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៨៤០០ ប.ប ចុះថ្ងៃទី ២៤–៣–៨៧ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិសំរោងក្នុង ឃុំ សំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៩០សេះ នៅក្នុងទីតាំងភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

ប្រការ ២ : លោក **ឡេង សេង** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

ប្រកាសលេខ ៤៩៥ ជក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **អេខ កុយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៦០៦៩ប.ប ចុះថ្ងៃទី ៣១-០១-៩៤ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិគរ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ១២០ សេះ នៅក្នុងទីតាំងភូមិ សំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **អេខ កុយ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

*****

ប្រកាសលេខ ៤៩៦ ជក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រ. ១ : អនុញ្ញាតអោយលោក **សុខ អិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៧៤៧៧៥ ប.ប ចុះថ្ងៃទី ១៦-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិទួលច្រនៀង ឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២ សេះ នៅក្នុងទីតាំងភូមិទួលច្រនៀង ឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក សុខ អឹម ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

*****

ប្រកាសលេខ ៤៩៧ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ហែម តែ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៦៧២៦៥ ប.ប ចុះថ្ងៃទី ១៥–៧–៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នភូមិរំដេ ឃុំ ស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង បន្តដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៥៥ សេះ នៅក្នុងទីតាំងភូមិរំដេ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ហែម តែ** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់ មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុង ករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

*****

ប្រកាសលេខ ៤៩៨ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **កែវ សុផាន** ជនជាតិខ្មែរ កាន់សញ្ជាតិកម្ពុជា សញ្ញាណប័ណ្ណលេខ ១៦៧៣៦៩ ប.ប ចុះថ្ងៃទី ១៦_៧_៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិរំផៃ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង បន្តដំណើរការកោងម៉ាស៊ីនកំណាំង ៥៥ សេះ នៅក្នុងទីតាំងភូមិរំផៃ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **កែវ សុផាន** ត្រូវបន្តដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ង៉ិត ឆ្រាំង

* * * * *

ប្រកាសលេខ ៥០០ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ឈឹម ហុង** ជាម្ចាស់មូលដ្ឋានផលិតទឹកកកដើម ដែលមានទីតាំងដីឡូត៍លេខ ២៤ ផ្លូវលេខ ២៦១សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ផ្ទេរសិទ្ធិគ្រប់គ្រងជូនលោក ម៉ុន **គង** វិញ និងប្តូរទីតាំង

ផលិតកម្មចាស់ទៅកាន់ទីតាំងថ្មី ផ្ទះសង់ថ្មី ផ្លូវលំ ភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ទទួលស្គាល់ **ម៉ិន គង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៦៦៨៦ ភព ចុះថ្ងៃទី ២០-៦-៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៧២អឺ០ ផ្លូវសុខហុក សង្កាត់មនោរម្យ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ជាម្ចាស់ឧស្សាហកម្មតូចផលិតទឹកកកដើម ដែលមានទីតាំងថ្មី ដូចមានចែងក្នុងប្រការ ១ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតិបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

*****

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ៤១២ អយក. ប្រក

ស្តីពីការបើកសាលាបឋមសិក្សា « គូមិថ្មី »

ជាខ្នងសម្ព័ន្ធរបស់សាលាបឋមសិក្សា « ឆ្នាត់ »

*****

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_៩៤
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត. ០៧៩៦_៥២ ចុះថ្ងៃទី ២៦_៧_៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះ ទូទៅ ១២ ឆ្នាំ ។
- បានឃើញលិខិតស្នើសុំរបស់មេភូមិ និង ប្រជាពលរដ្ឋភូមិថ្មី ចុះថ្ងៃទី ០៩_០១_៩៧ ខ.ប.ថ ៩៦ ចុះថ្ងៃទី ១០_១០_៩៦ និង សមត្ថកិច្ចមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ។
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តតាកែវ បើកសាលាឧបសម្ព័ន្ធ «ភូមិថ្មី» ដែលមានទីតាំងស្ថិតនៅក្នុងភូមិ ព្រៃជប់ ស្រុកបាទី ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ១៩៩៦_៩៧ នេះតទៅ ។

ប្រការ ២ : សាលាឧបសម្ព័ន្ធ «ភូមិថ្មី» ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា «ឆ្នាត់» ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកសាលាបឋមសិក្សា «ឆ្នាត់» ។

ប្រការ ៣ : សាលាឧបសម្ព័ន្ធ «ភូមិថ្មី» ត្រូវមានប្រធានក្រុមម្នាក់ជាជំនួយការរបស់លោកនាយកសាលាបឋមសិក្សា «ឆ្នាត់» ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ ប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុកបាទី នាយកសាលាបឋមសិក្សា «ឆ្នាត់» ប្រធានក្រុមសាលាឧបសម្ព័ន្ធ «ភូមិថ្មី» មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គាត សោភាន

* * * * *

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ៤១៣ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «គរ» មកជា

សាលាបឋមសិក្សា «ប៊ុន រ៉ានី ហ៊ុន សែន_ឃុំគរ» វិញ

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_៩៤
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លេខ សន.រកត. ០៧៩៦_៥២ ចុះថ្ងៃទី ២៦_៧_៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ ។
- បានឃើញលិខិតស្នើសុំរបស់សមាគមមាតាបិតាសិស្ស ទ្រទ្រង់សាលាបឋមសិក្សា «គរ» ចុះថ្ងៃទី ០៦_៣_៩៦ និង ចំណារបញ្ជូនរបស់អភិបាលខេត្តកំពង់ចាម លេខ ៣៩៩ ក.ច ចុះថ្ងៃទី ២៧_៣_៩៦ ។
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សាគរ ដែលមានទីតាំងស្ថិតនៅឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម មកជា «សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន ឃុំគរ» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពង់ចាម ប្រធានការិយាល័យអប់រំ យុវជន និង កីឡា ស្រុកព្រៃឈរ នាយកសាលាបឋម សិក្សា «ប៊ុន រ៉ានី ហ៊ុន សែន_ឃុំគរ» មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
គា សាមាន

*****

៥- នីតិការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ធ្នូសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ១១០/៩៧ ធកស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

*****

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា [illegible]កាស អោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦-១៨ ចុះថ្ងៃ[illegible] ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ ប្រូតេស្តង់ក្រុមជំនុំបេសកកម្ម សេចក្តីមេត្តាករុណា នៃព្រះគ្រិស្ទ របស់លោក អ៊ិន ហាំង ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាលខេត្តស្វាយរៀង លេខ ៨៥ ស.កិ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទនិកាយប្រូតេស្តង់ ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទឈ្មោះហៅថា «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទភូមិស្វាយតាយាន» មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិត្រពាំងត្រាច ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

ប្រ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទភូមិស្វាយតាយាន» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាគ្រិស្ទដែល មានលក្ខណៈជាសាសនាសុទ្ធសាធ ។

៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទភូមិស្វាយតាយាន» ត្រូវគោរពនឹងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួង ធម្មការ

និង សាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនានិង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តស្វាយរៀង និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចន្ទណារ័ត្ន

* * * * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ១១១/៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

* * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រ លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ក្រុមប្រឹយសម្ព័ន្ធ គ្រិស្តបរិស័ទកម្ពុជា របស់លោក មោខ សុខធំ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញលិខិតបញ្ជាក់ការយល់ព្រម អំពីទីតាំង របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ លេខ ១៤១៩ លសស ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៧ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ក្រុមប្រឹយសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជា ឈ្មោះហៅថា «ក្រុមជំនុំជីវិតថ្មី» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ១០៨ ផ្លូវលេខ ២៩៦ សង្កាត់ ទួលស្វាយព្រៃទី ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនៃព្រះវិហារឈ្មោះ «ក្រុមជំនុំជីវិតថ្មី» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ក្រុមជំនុំជីវិតថ្មី» ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការ

ខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពតតិយភ្ជិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ចន្ទ្រាវត្ត

* * * * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ : ១១២/៩៧ អធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

* * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយ ប្រូតេស្តង់ក្រុមសម្ព័ន្ធគ្រិស្ទាន ដំណឹងល្អខ្មែរ របស់លោក ខុន ចាន់នី ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាលខេត្តកណ្តាល លេខ ០៦០ សណ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ទនិកាយប្រូតេស្តង់ ក្រុមសម្ព័ន្ធគ្រិស្ទានដំណឹងល្អខ្មែរ ឈ្មោះហៅថា «ពន្លកថ្មី ព្រែកថ្មី» មួយកន្លែងដែលមានទីតាំង ស្ថិតនៅផ្លូវលំ ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «ពន្លកថ្មី ព្រែកថ្មី» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ពន្លកថ្មី ព្រែកថ្មី» ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវម៉ឺងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និង សាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័ន

ពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿ សាសនា និងសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ ៖ រាល់ការអនុវត្តទាំងឡាយណា ដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ ៖ នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះ អោយបានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ ៖ សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឃឿន វណ្ណរ័ត្ន

* * * * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល